សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# មូលហេតុនៃការកើតបទល្មើស នៅក្នុងសង្គមកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយៈ
និស្សិតឈ្មោះ លោក **វ៉ា ឈុនហុង**

សាស្ត្រាចារ្យណែនាំ
លោក **បណ្ឌិត ស៊ិន រិទ្ធ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Économiques**
**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# មូលហេតុនៃការកើតបទល្មើស នៅក្នុងសង្គមកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយៈ
និស្សិតឈ្មោះ លោក **វ៉ា ឈុនហុង**

សាស្ត្រាចារ្យណែនាំ
លោក **បណ្ឌិត ស៊ិន រិទ្ធ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **ទ៉ា ឈុនហុង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ជំនាន់ទី ២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំឱនកាយ សម្តែង នូវការគោរពដឹងគុណដ៏ជ្រាលជ្រៅបំផុតជូន ចំពោះ **លោកឪពុក និង អ្នកម្តាយ** ជាអ្នកមានគុណទាំងពីររបស់កូន។ ពិតណាស់ លោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវសេចក្តីស្រឡាញ់ មេត្តា ករុណា អប់រំទូន្មាន ផ្តល់ដំបូន្មានល្អៗដល់កូនឱ្យមានសេចក្តីអត់ធ្មត់ ព្យាយាម និងចេះតស៊ូនៅក្នុងជីវិត។ មិនត្រឹមតែប៉ុណ្ណោះ លោកអ្នកមានគុណទាំងពីរ ខិតខំប្រឹងប្រែង អស់ពីកម្លាំងកាយចិត្ត លះបង់គ្រប់បែបយ៉ាងទាំងស្មារតី ទាំងសម្ភារៈ និងទាំងប្រាក់កាស ដើម្បីឱ្យកូនទទួលបានចំណេះដឹងដ៏ប្រពៃថ្លៃថ្លាសម្រាប់ជាស្ពានចម្លង និងជាទ្រព្យដែលមិនអាចកាត់ថ្លៃបានសម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិទៅថ្ងៃអនាគត។

សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចន្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ រាមច្បង ព្រមទាំងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានលះបង់នូវរាល់ពេលវេលា និង កម្លាំងកាយចិត្ត ក្នុងការដឹកនាំ ណែនាំ បង្ហាត់បង្រៀន និងជួយជ្រោមជ្រែង យ៉ាងយកចិត្តទុកដាក់ចំពោះនិស្សិតទាំងអស់កន្លងមកឱ្យទទួលបានចំណេះដឹងដែលជាប្រទីបសម្រាប់បំភ្លឺផ្លូវនៅពេលអនាគត។

ជាពិសេស សូមថ្លែងអំណរគុណចំពោះ លោកបណ្ឌិត **ស៊ិន រិទ្ធ** ជាសាស្ត្រាចារ្យដឹកនាំ ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ ក្នុងការជួយណែនាំ ផ្តល់ដំបូន្មាន ផ្តល់យោបល់ និងបទពិសោធន៍ល្អៗ សម្រាប់យកខ្ញុំបាទ ជាពិសេស លោកបានជួយកែលម្អនូវកំហុសឆ្គងដែលកើតមានឡើង ដើម្បីឱ្យខ្ញុំបាទអាចរៀបចំក្នុងការស្រាវជ្រាវចងក្រងសារណាបញ្ចប់ការសិក្សាមួយនេះឡើង។

ជាទីបញ្ចប់ ខ្ញុំបាទ សូមលើកដៃប្រណម្យបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់នៅក្នុងលោកនេះ សូមតាមជួយថែរក្សា ការពារ ដល់លោកអ្នកមានគុណ និងសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ០៤ (បួន) ឆ្នាំ រួចមក ខ្ញុំបាទមានសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយទទួលបានចំណេះដឹងជំនាញនីតិសាស្ត្រលើមុខវិជ្ជាជាច្រើនទាំងផ្នែកនីតិឯកជន និងផ្នែកនីតិសាធារណៈ ក្រោមការខិតខំប្រឹងប្រែង ប្រកបដោយយកចិត្តទុកដាក់ អប់រំ ផ្ដល់ដំបូន្មាន ណែនាំ បង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យទាំងអស់។

ជាលទ្ធផល ដោយសារតែមានការជួយជ្រោមជ្រែង និងការយកចិត្តទុកដាក់ទាំងអស់នេះហើយ ធ្វើឱ្យខ្ញុំបាទមានឱកាសក្នុងការបង្ហាញស្នាដៃតាមរយៈការសិក្សាស្រាវជ្រាវ និងសរសេរចងក្រងសារណាមួយនេះលេចចេញជារូបរាងឡើង ដែលជាចំណងដៃក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្ររបស់ខ្ញុំបាទ នៅក្រោមប្រធានបទ "**មូលហេតុនៃការកើតបទល្មើសនៅក្នុងសង្គមកម្ពុជា**" ក្នុងគោលបំណង អាចជួយពង្រីកនូវចំណេះដឹងលើវិស័យ ព្រហ្មទណ្ឌ ក៏ដូចជាវិស័យយុត្តិធម៌ ឱ្យកាន់តែមានភាពងាយស្រួលច្បាស់ លាស់ និងស៊ីជម្រៅ ហើយសង្ឃឹមថា កម្រងសារណានេះនឹងចូលរួមជាចំណែកដ៏សំខាន់ សម្រាប់ជាឯកសារស្រាវជ្រាវបែបលក្ខណៈវិទ្យាសាស្ត្រថ្មីមួយ ដើម្បីជាមូលដ្ឋានដល់សិស្សនិស្សិត និងអ្នកស្រាវជ្រាវទាំងឡាយ ដែលកំពុងជួបនឹងលំបាកក្នុងការស្រាវជ្រាវរកឯកសារបំពេញបន្ថែម អំឡុងពេលសិក្សារៀនសូត្រ។

ក្នុងនាមខ្ញុំបាទជានិស្សិតដែលបានធ្វើការស្រាវជ្រាវ រៀបចំ ចងក្រងនូវសារណាមួយនេះឡើង ខ្ញុំបាទសូមទទួលស្គាល់ថា ទោះបីជាសារណាមួយនេះត្រូវបានចងក្រងឡើង ដោយការខិតខំ ព្យាយាម ប្រឹងប្រែង យកចិត្តទុកដាក់ និងផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយក៏អាចនៅតែមានការភ្លេចភ្លាំង ខុសឆ្គងត្រង់ចំណុចណាមួយដោយអចេតនាជាក់ជាមិនខាន។ ហេតុដូច្នេះ យើងខ្ញុំសូមធ្វើការអភ័យទោសពីសំណាក់ សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវ និងមិត្តអ្នកអានទាំងឡាយ ទុកជាមុន នូវរាល់កំហុសឆ្គង ចំណុចខ្វះខាតទៅលើឃ្លាឃ្លោងប្រយោគ ឬក៏មានកំហុសអក្ខរាវិរុទ្ធទាំងឡាយដែលអាចកើតមានឡើងដោយអចេតនា និងសូមស្វាគមន៍ជានិច្ចរាល់មតិយោបល់រិះគន់ក្នុងន័យស្ថាបនា ដើម្បីធ្វើការកែលម្អសារណាមួយនេះឱ្យកាន់តែប្រសើរឡើង។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធិពរដល់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ហើយយកចិត្តទុកដាក់ក្នុងការអានលើប្រធានបទនេះ សូមឱ្យជួបប្រទះតែសំណាងល្អ សុខភាពល្អ និងទទួលបាននូវជោគជ័យគ្រប់ភារកិច្ច។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហា ........ ១

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ២

៦. វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ ........ ២

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

ជំពូកទី១

ទិដ្ឋភាពទូទៅនៃបទល្មើសនៅក្នុងសង្គម

១. បទល្មើសដែលកើតមានជាញឹកញាប់ ........ ៤

១.១. បទល្មើស ចរាចរណ៍ ........ ៥

១.១.១. ការបើកបរដោយមិនប្រុងប្រយ័ត្ន និងក្នុងស្ថានភាពពិសេស ........ ៥

១.១.២. ការបើកបរដោយមិនគោរពច្បាប់ចរាចរណ៍ ........ ៥

១.២. បទល្មើស គ្រឿងញៀន ........ ៦

១.២.១. ការប្រើប្រាស់ និងការជួញដូរគ្រឿងញៀន ........ ៦

១.២.២. ការផលិត និងការរក្សាទុកគ្រឿងញៀន ........ ៨

២. បទល្មើសដែលមានលក្ខណៈបច្ចេកវិទ្យា និងមានលក្ខណៈពិសេស ........ ៨

២.១. បទល្មើស បច្ចេកវិទ្យា ........ ៨

២.១.១. ការឆបោក និងគំរាមកំហែងតាមប្រព័ន្ធអ៊ីនធើណែត ........ ៩

២.១.២. ការលួចចូលទិន្នន័យ និងការផ្សព្វផ្សាយ តាមប្រព័ន្ធអ៊ីនធើណែត ........ ៩

**២.២. បទល្មើសដែលមានលក្ខណៈពិសេស** ............ ១០

២.២.១. បទល្មើសសម្លាតប្រាក់ ............ ១០

២.២.២. បទល្មើស ហិរញ្ញប្បទានភេរវកម្ម ............ ១១

## ជំពូកទី២

## ការដាក់ទោស និងការអនុវត្តទោស

**១. ការដាក់ទោសចំពោះបទល្មើស** ............ ១៣

**១.១. ការដាក់ទោសចំពោះជនល្មើស** ............ ១៤

១.១.១. ការដាក់ទោសចំពោះជនដែលប្រព្រឹត្តធ្ងន់ធ្ងរ ............ ១៤

១.១.២. ការដាក់ទោសចំពោះជនដែលប្រព្រឹត្តស្រាល ............ ១៥

**១.២. ការអនុវត្តទោស** ............ ១៥

១.២.១. ការអប់រំ កែប្រែទណ្ឌិត ............ ១៦

១.២.២. ការសិក្សាជំនាញផ្សេងៗ ............ ១៦

**២. បទល្មើសកើនឡើង ឬក៏ថយចុះ** ............ ១៦

**២.១. ការកើនឡើងនៃបទល្មើស** ............ ១៧

២.២.១. ការមិនរាងចាល ............ ១៧

២.២.២. កាលៈទេសៈ នៃបទល្មើស ............ ១៧

**២.២. ភាពថយចុះនៃបទល្មើស** ............ ១៨

២.២.១. ការអនុវត្តច្បាប់បានល្អ ............ ១៨

២.២.២. ការអប់រំ កែប្រែ មានប្រសិទ្ធភាព ............ ១៨

## ជំពូកទី៣

## មូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គម

**១. បណ្ដាលមកពីវប្បធម៌ការអប់រំ និងច្បាប់** ............ ២០

**១.១. កត្តាវប្បធម៌ និងការអប់រំ** ............ ២០

១.១.១. កត្តាវប្បធម៌ ........................................................................................ ២០
១.១.២. កត្តាការអប់រំ ........................................................................................ ២១
**១.២. កត្តាច្បាប់ និងការផ្សព្វផ្សាយ** ........................................................................ ២១
១.២.១. កត្តាច្បាប់ ........................................................................................ ២២
១.២.២. កត្តាការផ្សព្វផ្សាយច្បាប់ ........................................................................ ២២
**២. មជ្ឈដ្ឋាន នៃការរស់នៅរបស់បុគ្គល** ........................................................................ ២៤
**២.១. ស្ថានភាពភូមិសាស្ត្រនៃការរស់នៅ** ........................................................................ ២៤
២.១.១. តំបន់អនាធិតេយ្យ ........................................................................................ ២៥
២.១.២. តំបន់ដាច់ស្រយាល ........................................................................................ ២៦
**២.២. ស្ថានភាពរីកចម្រើនបច្ចេកវិទ្យា** ........................................................................ ២៨
២.២.១. ទំនើបកម្មនៃសំភារៈនិយម ........................................................................ ២៨
២.២.២. បច្ចេកវិទ្យាទំនើប ........................................................................................ ២៩
**៣. វិធានការដោះស្រាយ និងវិធានការទប់ស្កាត់** ........................................................................ ៣០
**៣.១. យន្តការរបស់សង្គម** ........................................................................................ ៣០
៣.១.១. វិធានការស្មារតី ........................................................................................ ៣០
៣.១.២. វិធានការសំភារៈ ........................................................................................ ៣០
**៣.២. យន្តការឧក្រិដ្ឋវិទ្យា ច្បាប់ និងការអនុវត្តច្បាប់** ........................................................ ៣១
៣.២.១. វិធានការឧក្រិដ្ឋវិទ្យា ........................................................................................ ៣១
៣.២.២ វិធានការផ្លូវច្បាប់ និងការអនុវត្តច្បាប់ ........................................................................ ៣៣
**សេចក្តីសន្និដ្ឋាន** ........................................................................................ ៣៤
**អនុសាសន៍** ........................................................................................ ៣៧
**ឯកសារយោង**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការវិវត្តន៍នៃសង្គមនាពេលបច្ចុប្បន្ន បានធ្វើអោយមានភាពរីកចម្រើនសឹងតែគ្រប់វិស័យមិនថាលើវិស័យ សេដ្ឋកិច្ច នយោបាយ ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការណាមួយឡើយគឺមានភាពល្អប្រសើរ។ ហេតុអ្វី បានជាចាំសិក្សាអំពីការវិវត្តន៍នៃសង្គមនាពេលបច្ចុប្បន្ន តើវាមានភាពចាំបាច់សម្រាប់ការសិក្សាអំពីវា ដែលឬទេ? ចំពោះសង្គមការប្រៀបធៀប ការវិវត្តន៍ពីសម័យកាលមួយទៅសម័យកាលមួយអាចធ្វើអោយអ្នកសិក្សាបានដឹង អំពីអ្វីមួយ នឹងទទួលបានលទ្ធផលត្រលប់មកវិញរួមមានអ្វីៗទាំងអស់នៅក្នុងសកលលោកដូចជា ការវិវត្តផ្នែក សេដ្ឋកិច្ច នយោបាយ បច្ចេកវិទ្យា ការរស់នៅក្នុងសង្គមរួមទាំងការរីកចម្រើនផ្នែកវិទ្យាសាស្ត្រថែមទៀតអំឡុង ពេលពីអតីតកាលសង្គមក៏មានការវិវត្តន៍ជាច្រើនដែរ។ ប៉ុន្តែគ្រាន់តែមានភាពយឺត និងមិនទាន់មានភាពជឿន លឿនដូចបច្ចុប្បន្ននិងទៅអនាគតដោយសារកត្តានៃការវិវត្តន៍ទៅមុខនេះហើយបានជាអ្នកវិទ្យាសាស្ត្រ អ្នកប្រាជ្ញ ទស្សនៈវិទូ និងអ្នកសិក្សាស្រាវជ្រាវផ្នែកផ្សេងៗបានខិតខំស្វែងរកនូវរបបគំហើញថ្មី តកកម្ម និងយន្តការដំណោះ ស្រាយដែលកើតមាននៅពេលណាមួយទន្ទឹមនឹងភាពរីកចម្រើន និងការវិវត្តឈានទៅមុខជាបន្តបន្ទាប់នេះ ។

ដើម្បីជាចូលរួមក្នុងការអភិវឌ្ឍន៍ផ្នែកព្រហ្មទណ្ឌ និងផ្នែកឧក្រិដ្ឋវិទ្យាអោយកាន់តែមានភាពរីកចម្រើន ឡើងចំពោះសង្គមកម្ពុជាយើងនៅក្នុងគោលបំណងនៃការអភិវឌ្ឍន៍លើវិស័យច្បាប់ ការអនុវត្តច្បាប់អោយបាន ត្រឹមត្រូវនឹងជឿនលឿនមានលក្ខណៈជាវិទ្យាសាស្ត្រប្រកបដោយ ទ្រឹស្តីសង្គម វិទ្យាសាស្ត្រពិត បច្ចេកវិទ្យា និង ភាពរីកចម្រើនជឿនលឿននៅក្នុងការរស់នៅ ឲ្យសមស្របតាមបែបសង្គមសម័យទំនើប ជាពិសេស គឺការគ្រប់ គ្រងប្រទេសជាតិមួយប្រកបដោយភាពរុងរឿងទាំងការដឹកនាំលើវិស័យនានារួមផ្សំជាមួយសង្គមដែលមានច្បាប់ ល្អដែលទទួលបានការវាយតម្លៃជាសកលថាមានស្តងដារ ហើយជាកត្តាមួយដែលអាចទប់ស្កាត់ បង្ការការពារនូវ បទល្មើសដែលបាននឹងកំពុងវិវត្តន៍ទៅតាមបរិបទសង្គមតាមបែបបច្ចេកវិទ្យា នាសម័យបច្ចុប្បន្ន និងនាពេល អនាគត ប្រកបដោយភាពត្រឹមត្រូវតាមវិទ្យាសាស្ត្រ ដែលបានសិក្សាអំពីមូលហេតុនៃការកកើតបទល្មើសនៅក្នុង សង្គមកម្ពុជា រួមនេះបានចូលរួមមួយចំណែកផងដែរ។

## ២. ចំណោទបញ្ហា

ការវិវត្តន៍នៃសង្គម បានធ្វើអោយមានភាពល្អប្រសើរឡើងលើគ្រប់វិស័យ រួមផ្សំជាមួយនឹងបទល្មើស ដែលកំពុងតែកើនឡើងក្នុងពេលបច្ចុប្បន្ន និងបន្តកើតមកនាពេលអនាគត ដើម្បីទប់ស្កាត់បទល្មើស បង្កព្យសន កម្មដោយអំពើជាបទល្មើសនេះ តើសង្គមគប្បីមានវិធានការទប់ស្កាត់ និងបង្កាបទល្មើស មានដំណោះស្រាយ បែបណាចំពោះបទល្មើសទាំងនេះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធាននេះ មានគោលបំណងសំខាន់ក្នុងការស្វែងយល់ សិក្សាអោយបានស៊ីជម្រៅ អំពីមូលហេតុនៃការកកើតបទល្មើសដែលបានកើតឡើងនៅក្នុងសង្គមកម្ពុជា ឫសគល់នៃបទល្មើស មានកត្តារួមផ្សំអ្វីខ្លះដែលជួយសម្រួលដល់ការកើនឡើងនៃបទល្មើស។ ក្នុងគោលបំណងដើម្បីចូលរួមចំណែកអភិវឌ្ឍន៍វិស័យព្រហ្មទណ្ឌនៅកម្ពុជាអោយកាន់តែល្អប្រសើរឡើងដោយធ្វើការសិក្សាស្វែងរកបទល្មើសតាមបែបវិទ្យាសាស្ត្រផ្នែកឧក្រិដ្ឋវិទ្យា ដែលជាការស្រាវជ្រាវ ស្វែងរកវិធីសាស្ត្រ បង្កាទប់ស្កាត់ ឲ្យបានទាន់ពេលវេលា និងកុំអោយកើតមានឡើង ជាពិសេសជួយសម្រួលដល់អ្នកអនុវត្តច្បាប់ អោយមានភាពត្រឹមត្រូវ មានភាពយុត្តិធម៌ ដល់សង្គមជាតិ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវសម្រាប់សរសេរសារណា ដែលមានប្រធានបទ **"មូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គមកម្ពុជា"** ខ្ញុំបាទខិតខំស្រាវជ្រាវ និងសិក្សាដែលមានទំហំ និងដែនកំណត់ ដោយផ្តោតសំខាន់ទៅលើទិដ្ឋភាពទូទៅ នៃបទល្មើស ព្យសនកម្មដែលកើតចេញពីការអនុវត្តច្បាប់ និងមូលហេតុដែលជាកត្តាបណ្តាលឲ្យកើតមានបទល្មើសនៅក្នុងសង្គមកម្ពុជា ជាពិសេសគឺជាយុត្តិសាស្ត្រ នៅក្នុងការដោះស្រាយចំពោះបទល្មើសដែលបានកើតឡើង ដោយអនុលោមតាមច្បាប់ព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ វិទ្យាសាស្ត្រឧក្រិដ្ឋវិទ្យា និងបទដ្ឋានដោយឡែកផ្សេងទៀត នៃព្រះរាជាណាចក្រកម្ពុជា និងអន្តរជាតិ ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ខ្ញុំបាទបានសិក្សាស្រាវជ្រាវលើប្រធានបទនេះ ដើម្បីទទួលបានចំណេះដឹងផ្នែកទ្រឹស្តី និងចំណេះដឹងទាក់ទងនឹងការអនុវត្ត ព្រមទាំងទទួលបានបទពិសោធន៍ ចំពោះមូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គមកម្ពុជា ឱ្យកាន់តែមានភាពច្បាស់លាស់ជាងមុនថែមទៀត ហើយការស្រាវជ្រាវប្រធានបទនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ ខ្ញុំបាទ ពីព្រោះដើម្បីឈានដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រប្រកបដោយភាពជោគជ័យ និងដើម្បីចូលរួមចំណែកអភិវឌ្ឍន៍វិស័យយុត្តិធម៌នៅកម្ពុជា ឱ្យមានលក្ខណៈកាន់តែល្អប្រសើរឡើងថែមទៀតផង។ ជាពិសេសខ្ញុំបាទសង្ឃឹមថាសមិទ្ធផលនៃការសិក្សាស្រាវជ្រាវប្រធានបទនេះអាចទុកជាឯកសារមួយសម្រាប់ប្អូនៗដែលជានិស្សិតជំនាន់ក្រោយៗ សម្រាប់ការសិក្សាស្វែងយល់អំពីមូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គមកម្ពុជា ដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់លាស់ និងមានភាពត្រឹមត្រូវបន្ថែមទៀត។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ក្នុងការសិក្សាទៅលើប្រធានបទនេះ ខ្ញុំបាទបានធ្វើការសម្ភាសន៍ជាមួយ អ្នកអនុវត្តច្បាប់ ដូចជាសមត្ថកិច្ចដែលពាក់ព័ន្ធវិស័យព្រហ្មទណ្ឌ មាន ប៉ូលីស ទាហាន ... អ្នកបម្រើការក្នុងស្ថាប័នមួយចំនួន ចៅក្រម ព្រះរាជអាជ្ញា និងសាស្ត្រាចារ្យដែលបានបង្ហាត់បង្រៀន ជាពិសេសលោកគ្រូ ណែនាំផ្ទាល់ក្នុងការសរសេរសារណានេះ។ ខ្ញុំបាទក៏បានធ្វើផងដែរ ការប្រមូលរាល់ឯកសារដែលបានពីការចូលរួមសិក្ខាសាលា ឧទ្ទេសនាមដោយ មន្ត្រីក្រប

ខណ្ឌក្រសួង មន្ទីរ និងបុគ្គលពាក់ព័ន្ធដទៃ ព្រមទាំងប្រមែប្រមូលឯកសារគតិយុត្ត (ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសៀវភៅដែលពាក់ព័ន្ធវិស័យព្រហ្មទណ្ឌ)។ លើសពីនេះទៅទៀត ខ្ញុំបានធ្វើការស្រាវជ្រាវ និងប្រមូលឯកសារដែលពាក់ព័ន្ធពីបណ្ណាល័យនៃសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងឯកសារមួយចំនួនផ្សេងទៀតដែលទទួលបានតាមរយៈប្រព័ន្ធអេឡិចត្រូនិច។

បន្ទាប់ពីបានប្រមូលទិន្នន័យខាងលើរួច ខ្ញុំបាទយកទិន្នន័យដែលទទួលបានមកធ្វើការសិក្សាវិភាគ និងប្រៀបធៀបជាមួយទ្រឹស្តី និងការអនុវត្ត ដែលបានសិក្សាកន្លងមកពីសាស្ត្រាចារ្យ ដើម្បីធ្វើការវិភាគរកចំណុចខ្លាំងចំណុចខ្សោយ ដើម្បីឈានឆ្ពោះទៅរកការសន្និដ្ឋានជារួម និងផ្តល់អនុសាសន៍។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាចំពោះប្រធានបទខាងលើស្តីអំពី **"មូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គមកម្ពុជា"** ខ្ញុំបាទសូមធ្វើការបែងចែកជា ០៣ (បី) ជំពូក ដូចខាងក្រោម៖

- **ជំពូកទី០១ ៖ ទិដ្ឋភាពទូទៅនៃបទល្មើសនៅក្នុងសង្គមកម្ពុជា**
- **ជំពូកទី០២ ៖ ការដាក់ទោស និងការអនុវត្តទោស**
- **ជំពូកទី០៣ ៖ មូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គមកម្ពុជា**

# ជំពូកទី១
# វិជ្ជាភាពខ្ពង់ខ្ពស់នៃបទល្មើស
# នៅក្នុងសង្គម

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃបទល្មើសនៅក្នុងសង្គម

បាតុភូតសង្គមដែលកើតឡើងល្មើសច្បាប់ព្រហ្មទណ្ឌជារូបភាពរបស់បទល្មើសផ្សេងៗ និងបានប្រព្រឹត្ត ដោយជនល្មើសក្រោមមជ្ឈដ្ឋានរបស់សង្គម។ បាតុភូតដែលបានបំពានច្បាប់ និងសណ្ដាប់ធ្នាប់សង្គមជាហេតុ ដែលបង្កអោយមានបទល្មើសកើតឡើងនេះហើយហៅថា ផលវិបាកដែលបណ្ដាលមកពីមូលហេតុ និងលក្ខខណ្ឌ របស់សង្គម។

បទល្មើសវាបង្កគ្រោះថ្នាក់ដល់សង្គមហើយប្រឆាំងនូវអ្វីដែលច្បាប់បានហាមឃាត់ការប្រព្រឹត្តបទល្មើស អាចក្នុងដំណាក់កាលតែមួយ ឬដំណាក់កាលផ្សេងគ្នា។ ដំណើរការវិវត្តន៍បទល្មើស និងជុំវិញឲ្យមានការផ្លាស់ប្ដូរ ក្រឹត្យក្រមព្រហ្មទណ្ឌ។ ចំពោះការផ្លាស់ប្ដូរច្បាប់ជាវិធានការមួយដែលធ្វើការទប់ស្កាត់បទល្មើសគួរចាប់អារម្មណ៍ ថាកាលណានិយាយពីបទល្មើស គឺសំដៅទៅលើភាពអន្តរាយនៃបាតុភូត។ បុគ្គលដែលបានប្រព្រឹត្តបទល្មើសគឺ មានទិសដៅផ្សេងៗគ្នាមានដែនកំណត់គោលដៅជាពិសេសមានមធ្យោបាយខុសគ្នា ការបំពានដែលមានលក្ខណៈ សម្បត្តិដោយឡែកពីគ្នាឲ្យបទល្មើសមានបរិមាណ និងគុណភាពខុសៗគ្នា។ ការស្រាវជ្រាវរកកំរិតនៃបទល្មើសគឺ ផ្ទៀងផ្ទាត់ទៅបរិមាណដែលបានប្រព្រឹត្តបទល្មើសដូចជាអ្នកប្រព្រឹត្តផ្ទាល់ អ្នកចូលរួម អ្នកសមគំនិត និងអ្នកផ្ដើម គំនិតជាដើម។[1]

## ១. បទល្មើសដែលកើតមានជាញឹកញាប់

បទល្មើសដែលកើតឡើងជាញឹកញាប់នៅក្នុងសង្គមនាពេលបច្ចុប្បន្នតាមរយៈការសង្កេត និងការសិក្សា ស្រាវជ្រាវភាគច្រើនកើតចេញពីការមិនគោរពច្បាប់ ការមិនអនុវត្តតាមសណ្ដាប់ធ្នាប់សាធារណៈសង្គម ដែលបង្ក អោយកើតមានបាតុភូតហេតុការណ៍ជាបទល្មើសឡើង។ តាមរយៈមធ្យោបាយទៅតាមប្រភេទនៃបទល្មើសនីមួយៗ និងព្យសនសកម្មនៃអំពើល្មើសទាំងនោះក៏អាចមានកត្តាគួបផ្សំពី អត្តចរិត អាយុ ភេទបុគ្គលជាដើម។[2] ចំពោះបទ ល្មើសមួយចំនួនដែលបានលើកមកសិក្សានៅពេលនេះមិនមែនមានន័យថាមានតែមួយពីរ ឬបី នេះទេ។ គ្រាន់តែ ជាការលើកយកមួយចំនួនមកសិក្សាដោយសារតែបទល្មើសទាំងនេះកំពុងតែមានចរិតគ្រោះថ្នាក់នៃអំពើល្មើសដែល បង្កលក្ខណៈស្មុគស្មាញកើតឡើងជាញឹកញាប់ដែលទាមទារឲ្យមានការសិក្សាអំពីវាដោយលក្ខណៈ វិទ្យាសាស្ត្រ បច្ចេកទេស និងជំនាញលើវិស័យនីមួយៗជាពិសេស។ ព្យសនកម្មដែលបានបង្កអោយមានបញ្ហាដ៏ការអនុវត្ត ចំពោះសង្គមជាតិដូចជា បទល្មើសចរាចរណ៍ការបើកបរដោយមិនគោរពច្បាប់នៅពេលមានគ្រោះថ្នាក់ក្នុងអំឡុង

[1] មាត្រា២៨,២៩, ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[2] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

ពេលបើកបរគឺព្យសនកម្មមិនមែនត្រឹមតែបុគ្គលម្នាក់ ឬមួយក្រុមនោះទេបានប៉ះពាល់ទៅដល់អ្នកដទៃសណ្ដាប់ធ្នាប់សាធរណៈល្អ។ ដូចគ្នាផងដែរចំពោះបទល្មើសគ្រឿងញៀនវាជាបញ្ហាធំបំផុតសម្រាប់ការដឹកនាំមិនមែនតែនៅក្នុងប្រទេសកម្ពុជាយើងទេសូម្បីតែពិភពលោកក៏មានការព្រួយបារម្ភជាខ្លាំងពាក់ព័ន្ធបទល្មើសនេះ។ ដោយមានការបង្កើតជាក្រុមសិក្សាស្រាវជ្រាវបទល្មើសគ្រឿងញៀន មានលក្ខណៈជាអន្តរជាតិដើម្បីទប់ស្កាត់នូវអំពើល្មើសនេះផងដែរ។ ត្រលប់មកការដឹកនាំសង្គមកម្ពុជាយើងវិញប្រសិនបើមានបទល្មើសគ្រឿងញៀនកើតឡើងជាបន្តបន្ទាប់ច្រើនឡើងៗពីមួយឆ្នាំទៅមួយឆ្នាំសំណួរដែរយើងត្រូវសួរថាតើផលនៃបទល្មើសនេះបានប៉ះពាល់អ្វីខ្លះដល់សង្គមជាពិសេសយុវជនមួយចំនួនជាទំពាំងស្នងឬស្សីដែលមិនសូវយល់ដឹងអំពី ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន។

**១.១. បទល្មើស ចរាចរណ៍**

បទល្មើសចរាចរណ៍ សំដៅលើសកម្មភាពមួយដែលកើតឡើងពីការបើកបរដោយមិនប្រុងប្រយ័ត្នល្មើសនឹងច្បាប់។ ហេតុអ្វីបានជាបទល្មើសចរាចរណ៍ កើតឡើងជាញឹកញាប់យ៉ាងនេះ? ជាការពិតណាស់ដោយសារតែមានកត្តាជាដែលបានរួមផ្សំគ្នាបង្កអោយមានបទល្មើសនេះកើតឡើងដូចជា៖

**១.១.១. ការបើកបរដោយមិនប្រុងប្រយ័ត្ន និងក្នុងស្ថានភាពពិសេស**

ការបើកបរដោយមិនប្រុងប្រយ័ត្ន សំដៅលើការបើកបរមួយដែលមិនបានប្រើប្រាស់នូវស្មារតីនៅក្នុងការបើកបរមួយដ៏ត្រឹមត្រូវដូចជា ការបើកបរដោយជជែកគ្នាមិនបានប្រុងប្រយ័ត្ននៅលើដងផ្លូវការប្រើប្រាស់ទូរស័ព្ទក្នុងការបើកបរជាដើម។[3]

ការបើកបរក្នុងស្ថានភាពពិសេស វាអាចទាក់ទងអារម្មណ៍របស់អ្នកបើកបរដោយសារកត្តាខាងក្រៅអាចបណ្ដាលមកពីការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងពេលបើកបរ គ្រឿងញៀនករណីនេះក៏អាចកើតឡើងពីបញ្ហាសុខភាពផងដែរដែលបណ្ដាលអោយមានបទល្មើសកើតឡើងតាមទិដ្ឋភាពនៃបទល្មើសដែលបានបង្កហេតុ។

**១.១.២. ការបើកបរដោយមិនគោរពច្បាប់ចរាចរណ៍**

ច្បាប់ចរាចរណ៍ បានចែងច្បាស់អំពីសកម្មភាពនៃការបើបរដោយមានភាពត្រឹមត្រូវដោយមានការកំណត់ច្បាស់ពីស្លាកសញ្ញាចរាចរណ៍ ការប្រើប្រាស់ផ្លូវថ្នល់ ការប្រើប្រាស់ល្បឿន អាយុ និងមានប័ណ្ណបើកបរត្រឹមត្រូវជាអាទិ៍បានអាចបើកបរបាន។ តែចំពោះការអនុវត្តជាក់ស្តែងវិញអ្នកបើកបរមួយចំនួនមិនបានអនុវត្តនូវការបើកបរបើកលើសល្បឿនកំណត់ មិនគោរពភ្លើងស្តុប ផ្លាកសញ្ញាជាដើមនេះហើយដែលជាហេតុដែលបណ្ដាលអោយមានបទល្មើសចរាចរណ៍កើតឡើងជារៀងរាល់ថ្ងៃដែលជាហេតុបង្កការលំបាកនៅក្នុងការអនុវត្តច្បាប់ ។[4]

---

[3] មាត្រា ២៥ ច្បាប់ចរាចរណ៍ផ្លូវគោក

[4] មាត្រា ៤ ច្បាប់ចរាចរណ៍ផ្លូវគោក

### ១.២. បទល្មើស គ្រឿងញៀន

គ្រឿងញៀន សំដៅដល់រុក្ខជាតិញៀន សារធាតុញៀន និងសារធាតុគីមីផ្សំទាំងឡាយដែលបានកំណត់ក្នុងតារាងដែលជាឧបសម្ព័ន្ធច្បាប់។

ចំពោះគ្រឿងញៀនគឺជាបញ្ហាធំបំផុតសម្រាប់ពិភពលោកមិនថាប្រទេសណាឡើយវាជារឿងមួយសំខាន់បំផុតដោយសារតែផលនៃការប៉ះពាល់លើអ្នកប្រើប្រាស់ខ្លាំង នឹងមិនអាចមានអ្វីជួយសង្គ្រោះនូវគុណវិបត្តិនេះបានឡើយចំពោះអ្នកបានប្រើប្រាស់គ្រឿងញៀន។ អាចកំណត់បានថាវាគឺជាឃាតករលាក់មុខមួយប្រភេទដែលបាន ជះឥទ្ធិពលទៅដល់ក្រុមគ្រួសារ សង្គមជាតិ ពិភពលោកជាពិសេសគឺខ្លួនបុគ្គលដែលបានប្រើប្រាស់ផ្ទាល់តែម្តង។ តើអ្វីទៅជាគ្រឿងញៀនហេតុអ្វីបានជាមានការទាក់ទងគ្នា នឹងការកកើតបទល្មើសនៅក្នុងសង្គមដូចខាង ក្រោមៈ

#### ១.២.១. ការប្រើប្រាស់ និងការជួញដូរគ្រឿងញៀន

**ការប្រើប្រាស់គ្រឿងញៀន** សំដៅទៅលើអ្នកដែលបានប្រើប្រាស់គ្រឿងញៀនហើយស្ថិតក្នុងស្ថានភាពញៀនគ្រឿងញៀន។ ទិដ្ឋភាពនៅក្នុងសង្គមនាពេលបច្ចុប្បន្នការប្រើប្រាស់គ្រឿងញៀនមានភាពសមាសភាពច្រើនគួរ អោយកត់សម្គាល់តាមរយៈទិន្ន័យការសិក្សាស្រាវជ្រាវពីនាយកដ្ឋានប្រឆាំងបទល្មើសគ្រឿងញៀនបានបង្ហាញ ថាយុវជនកម្ពុជាជាច្រើនកំពុងតែដើរចូលក្នុងបញ្ហានេះដោយមិនបានដឹងខ្លួន។ ដោយមានកត្តាជំរុញដូចជាការបាក់ទឹកចិត្ត តាមរយៈមិត្តភក្តិ ការងារ ស្ថានភាពសេដ្ឋកិច្ច គ្រួសារទីកន្លែងដែលបុគ្គលនោះកំពុងតែរស់នៅជាដើម បើយើងក្រឡេកមើលទៅតាមរយៈការចុះផ្សាយ ពត៌មាន កាសែត និងបណ្តាញសង្គមផ្សេងពីមួយថ្ងៃទៅមួយថ្ងៃ គឺបទល្មើសគ្រឿងញៀនកើតឡើងគ្មានពេលណាមួយឈប់ឡើយ។[5]

ការប្រើប្រាស់គ្រឿងញៀននៅក្នុងសង្គមមានរូបភាពជាច្រើនដែលកំពុងតែបានកើតឡើងដូចជា ការសេពគប់មិត្តភក្តិ ស្ថានភាពសេដ្ឋកិច្ច បញ្ហានៅក្នុងក្រុមគ្រួសារមជ្ឈដ្ឋាននៃការរស់នៅ ការមិនសូវទទួលបានការអប់រំ កត្តាផ្ទាល់ខ្លួនរបស់បុគ្គលនោះជាពិសេសកាលៈទេសៈនៃការប្រើប្រាស់ដោយមិនបានដឹងខ្លួន តាមរយៈការទៅធ្វើជាពលករ កម្មករទាំងក្នុងប្រទេស និងក្រៅប្រទេសពីព្រោះការប្រើប្រាស់កម្លាំងពលកម្ម។ ម្ចាស់អាជីវកម្មមួយចំនួនគេសូវខ្វល់ខ្វាយអំពីបញ្ហាសុខភាពឡើយការបម្រើសេវាកម្ម ក្លឹបកម្សាន្ត រង្គសាលការប្រើប្រាស់នូវសារធាតុគ្រឿងញៀនក៏មានសញ្ញាណនៃបទល្មើសនេះកើតឡើងផងដែរ។ ដោយបានលេចរូបភាពជាបន្តបន្ទាប់នៅពេលដែលមានវិធានការចុះឆែកឆេរទីតាំងមួយចំនួនដែលមានការសង្ស័យថាជាកន្លែងប្រាស់សារធាតុទាំងនេះ។[6]

---

[5] មាត្រា៤ ច្បាប់ស្តីពីការត្រួតពិនិតគ្រឿងញៀន

[6] កាសែតនគរវត្ត ចុះថ្ងៃ១៧ ខែមិថុនា ឆ្នាំ២០១៩

ចំពោះការចូលរួមចំណែកដោយប្រយោលមួយទៀតហើយមានលក្ខណៈធ្ងន់ធ្ងរបំផុតនោះ គឺតាមរយៈការប្រព័ន្ធនៃការផ្សព្វផ្សាយបណ្ដាញសង្គម ការផ្សាយពត៌មានជាដើម។ ហេតុអ្វីបានជាការផ្សព្វផ្សាយ អោយបានដឹង តែបែរជាកើតទៅជាបទល្មើសវិញ? បើយើងវិភាគមួយជ្រុងប្រាដកណាស់មានប្រយោជន៍បានទទួលដឹងថាមានបទល្មើសកើតឡើង។ តែបទល្មើសមួយចំនួនវាបានបង្កប់ខ្លួនដោយសារតែការបង្ហាញបែបនេះដោយមិនបានផ្សាយអោយយល់ច្បាស់ពីផលវិបាក។ ឧទាហរណ៍ៈមានវីដេអូរបស់ក្មេងៗមួយក្រុមសំដែងពីការប្រើប្រាស់គ្រឿងញៀន និងមានការវាយតបគ្នាទៅវិញទៅមក។ ចំពោះករណីនេះគោលបំណងនៃការផលិតវីដេអូ គឺចង់បង្ហាញថាធ្វើជាការអប់រំតែយុវជនក្មេងៗមួយចំនួនបែរជាយកសកម្មភាពបែបនេះក្នុងការធ្វើត្រាប់តាមទៅវិញ។

**ការជួញដូរ** សំដៅដល់ការផ្ដល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឫដោះដូរការដោះដូរនូវគ្រឿងញៀន។ តាមរយៈការសិក្សាស្រាវជ្រាវការជួញដូរមានលក្ខណៈ និងរូបភាពជាច្រើនអាចស្រដៀងគ្នានិងការប្រើប្រាស់ដែរគ្រាន់តែបុគ្គលទាំងនោះ គឺជាចែកចាយទៅជនរងគ្រោះដែលបានប្រើប្រាស់នូវសារជាតុញៀនទាំងនោះ មានន័យថាអ្នកជួញដូរគឺអ្នកដែលចែកចាយ មកទីផ្សារខាងក្រៅតាមគ្រប់មធ្យោបាយ តាមរយៈការទាក់ទាញពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត។[7]

ការជួញដូរមានពីសណ្ឋានៈ ទី១.គឺជាការជួញដូរដែលមានលក្ខណៈជាអាជីវកម្ម និងទី២.ការជួញដូរតាមរយៈការចែកចាញទ្រង់ទ្រាយតូចៗ។

ទី១.គឺជាការជួញដូរ ដែលមានលក្ខណៈជាអាជីវកម្មប្រភេទបែបនេះក៏អាចចាត់ទុកដូចគ្នា នឹងកន្លែងផលិតផងដែរគ្រាន់តែសកម្មភាពមួយជាការផលិត មួយជាការជួញដូរ។ រូបភាពនេះភាគច្រើនគឺមេឈ្មួញ ដែលទទួលបាននាំចូលពីកន្លែងផលិតមកចរាចរទៅតាមតំបន់ នឹងទីតាំងទីមួយៗដែលជាការកាន់កាប់របស់ពួកគេ ឫក៏ជាការជួញដូរតាមរយៈការធ្វើការឆ្លងកាត់ដើម្បីជាធ្វើការងាយស្រួលដល់បុគ្គលដែលជាឈ្មួញដទៃ ឫឈ្មួញអន្តរជាតិនៅក្នុងលក្ខខណ្ឌណាមួយ។

ទី២. ការជួញដូរតាមរយៈ ការចែកចាញទ្រង់ទ្រាយតូចៗ គឺជាស្ថានភាពមួយដែលសកម្មភាពបែបនេះធ្វើការចែកចាយនៅក្នុងស្រុកតាមរយៈទីតាំងរបស់បុគ្គលនោះកាន់កាប់រៀងៗខ្លួន។ រូបភាពបែបនេះភាគច្រើនតាមទីកន្លែងអនាធិបតេយ្យ គ្មានសណ្ដាប់ធ្នាប់ ពុំសូវមានសន្តិសុខល្អជាដើម។ វាមានលក្ខណៈងាយស្រួលដល់បទល្មើសកើតឡើងដោយមិនសូវមានការចូលទៅដល់ទីតាំងគេមិនខ្វល់ខ្វាយនេះជាប្រភពខ្លះនៃបទល្មើសលក្ខណៈបែបនេះ។

[7] មាត្រា៤ ច្បាប់ស្ដីពីការត្រួតពិនិតគ្រឿងញៀន

### ១.២.២. ការផលិត និងការរក្សាទុកគ្រឿងញៀន

**ការផលិត** សំដៅដល់ការចម្រាញ់ ឬការញែកសារធាតុញៀនចេញពីរុក្ខជាតិ ការបន្សុទ្ធ ការបំប្លែង ការផ្សំ ឬសកម្មភាពតាមគ្រប់រូបភាពផ្សេងទៀតដើម្បីទទួលបាននូវគ្រឿងញៀន។ ចំពោះកន្លែងសម្រាប់ផលិតគ្រឿងញៀន គឺជាក្បាលម៉ាស៊ីននៃបទល្មើសនេះ ដោយហេតុថាទាល់តែមានការផលិត ទើបមានការរក្សាទុក ការចែកចាយ ការជួញដូរ និងឈានដល់អ្នកប្រើប្រាស់។ ជាទូទៅទីតាំងដែលផលិតជាកន្លែងដែលមានសុវត្ថិភាពខ្ពស់ និងមិនសូវមានការចាប់អារម្មណ៍ពីខាងក្រៅពេលខ្លះវាអាចបង្កប់នៅក្នុងរូបភាព ជាអាជីវកម្មស្របច្បាប់ណាមួយ អាចលាក់ បាំងពីសមត្ថកិច្ចបានខ្ពស់។

**ការរក្សាទុក** សំដៅដល់ការកាន់កាប់ ការលាក់ទុក សន្និធិ និងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀតនូវគ្រឿងញៀន។ ករណីដែលមានការរក្សាទុកនូវសារធាតុ គ្រឿងញៀន វាជាការសម្រួលដល់បទល្មើសដែលច្បាប់កំពុងតែស្រាវជ្រាវលើបុគ្គលទាំងនោះ។[8]

## ២. បទល្មើសដែលមានលក្ខណៈបច្ចេកវិទ្យា និងមានលក្ខណៈពិសេស

នាពេលបច្ចុប្បន្ន បច្ចេកវិទ្យាកាន់តែជឿនលឿនឈានទៅមុខជាបន្តបន្ទាប់ដែលបង្កលក្ខណៈងាយស្រួលក្នុងការរស់នៅប្រចាំថ្ងៃមិនតែប៉ុណ្ណោះ បច្ចេកវិទ្យាបានធ្វើអោយមានការវិវត្តន៍នៃផ្នត់គំនិតរបស់ប្រជាជនទូទាំងពិភពលោក។ ទន្ទឹមនឹងការវិវត្តនេះបទល្មើសថ្មីមួយក៏បានកើតឡើងផងដែរនោះគឺជាបទល្មើសដែលពាក់ព័ន្ធទៅនឹងបច្ចេកវិទ្យាការជឿនលឿននៃភាពសំបូរបែបនៃសំភារៈនិយមដូចជាការប្រើប្រាស់នូវទូរស័ព្ទ ទូរអេជីអេមប្រព័ន្ធបណ្តាញសង្គមជាដើម។ល។ បានជំរុញអោយកើតបទល្មើសតាមរយៈសកម្មភាពនៃការប្រើប្រាស់របស់ទាំងនោះដោយជនល្មើសបានបង្កើត និងរៀបចំគម្រោងនានាជាច្រើនដើម្បីដើរអោយទាន់បច្ចេកទេសទំនើបនេះផងដែរ។

### ២.១. បទល្មើស បច្ចេកវិទ្យា

បទល្មើសបច្ចេកវិទ្យា គឺជាបទល្មើសមួយថ្មីដែលកំពុងតែកើតមានច្រើនហើយមានព្យសនកម្មធ្ងន់ធ្ងរ និងបង្កអសន្តិសុខដល់សង្គមភាពគ្មានសណ្តាប់ធ្នាប់លើប្រព័ន្ធអ៊ីធើណេតមួយផ្នែកនាពេលបច្ចុប្បន្ននេះ ដោយហេតុថាការប្រព្រឹត្តបទល្មើសនីមួយៗ មានរូបភាពផ្សេងពីគ្នាពីបទល្មើសមួយទៅបទល្មើសមួយទៀតទៅតាមបរិបទនៃអំពើល្មើស សកម្មភាពនៃការប្រព្រឹត្ត កើតមានឡើង ជាពិសេសបទល្មើសមួយនេះ គឺបច្ចេកវិទ្យាកាន់តែរីកចម្រើនពេលនោះហើយបទល្មើសក៏កាន់តែមានច្រើនហើយជនរងគ្រោះពីអំពើនោះក៏មិនតិចដែរ។ កាលណាបទល្មើសកើតឡើងវាមានរូបភាពមួយចំនួនដូចជា៖

[8] មាត្រា៤ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

### ២.១.១. ការឆបោក និងគំរាមកំហែងតាមប្រព័ន្ធអ៊ីនធើណែត

**ការឆបោកតាមប្រព័ន្ធអ៊ីនធើណែត** គឺជាការប្រើប្រាស់នូវកលល្បិចអោយជនរងគ្រោះជឿទុកចិត្តចំពោះសកម្មភាពណាមួយដែលនឹងកើតឡើងនាពេលខាងមុខ។ បន្ទាប់មកជនល្មើសក៏បានប្រើប្រាស់នូវវិធីមធ្យោបាយក្នុងការឆបោក ឧទាហរណ៍៖ ការផ្ញើរបស់ណាមួយមកអោយជនរងគ្រោះ ឬមានអ្នកណាម្នាក់ស្គាល់ផ្ញើអោយដោយមានលក្ខខណ្ឌជាមុនត្រូវទទួលបានរបស់នោះគឺតម្រូវឲ្យមានការផ្ញើរប្រាក់ជាមុន ឬអោយជនរងគ្រោះទៅទាក់ទងធ្វើអ្វីមួយហើយទើបទទួលបានដោយរូបភាពទាំងនេះគឺមានលក្ខណៈពេញនិយម ចំពោះប្រទេសយើងនៅក្នុងបរិបទនៃបទល្មើសបច្ចេកវិទ្យានេះ។[9]

**ការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធើណែត** ចំពោះបទល្មើសនេះគឺបានស្តែងឡើងនូវអំពើល្មើស ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌដូចគ្នាផងដែរ។ ដោយការគំរាមគំហែងនេះមានរូបភាពដូចជាមានការចាប់ខ្លួនបុគ្គលណាមួយ ឬជាសកម្មភាពលួចចូលទៅក្នុងប្រព័ន្ធទិន្នន័យរបស់បុគ្គលណាមួយហើយបានដឹងពីការសំងាត់បុគ្គលណាមួយដោយបានប្រើប្រាស់នូវមធ្យោបាយតាមរយៈការគំរាមកំហែងតាមរយៈការផ្ញើរសារ ឬតេទៅនិយាយផ្ទាល់ជា មួយជនរងគ្រោះថានឹងបង្ហាញ ឬគំរាមកំហែងសម្លាប់ក្នុងរូបភាពណាមួយដើម្បីជនល្មើសទទួលបានផលពីអំពើល្មើសនោះ។[10]

### ២.១.២. ការលួចចូលទិន្នន័យ និងការផ្សព្វផ្សាយ តាមប្រព័ន្ធអ៊ីនធើណែត

ការលួចចូលទៅក្នុងប្រព័ន្ធទិន្នន័យ របស់បុគ្គលណាមួយវាគឺជាមួយដែលខុសច្បាប់ដោយឡែកជនល្មើសនៅក្នុងការប្រព្រឹត្តបទល្មើសបានព្យាយាមចូលទៅដើម្បីដឹងអំពីពត៌មានរបស់ជនរងគ្រោះ ក្នុងគោលដៅដើម្បីយកទិន្នន័យ ឬអ្វីផ្សេងទៀតដែលជាការសំងាត់ដើម្បីបង្ហាញចេញមកក្រៅក្នុងគោលបំណងចង់បានអ្វីពីជនរងគ្រោះទៅតាមគម្រោងការនីមួយៗ។

ការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធើណែត៖ ចំពោះការផ្សព្វផ្សាយនូវទិន្នន័យ ការសំងាត់ ឬពត៌មានផ្ទាល់ខ្លួនរបស់បុគ្គលដទៃដោយគ្មានការអនុញ្ញាតនោះវាជាបទល្មើសមួយដែលបានកើតឡើងរួចហើយ។ នៅពេលដែលជនល្មើសបានប្រព្រឹត្តរួចហើយយកទៅផ្សព្វផ្សាយជាសាធារណៈ ឬបង្ហាញដល់បុគ្គលក្រុមណាមួយនោះហើយគឺជាការផ្សព្វផ្សាយផលនៃបទល្មើសដែលជនរងគ្រោះទទួលរងព្យសនកម្មពីអំពើដោយសកម្មភាព ក្នុងរូបភាពតាមទម្រង់បែបណាក៏ដោយ។[11]

---

[9] កាសែត កម្ពុជាថ្មី ចុះថ្ងៃទី៥ ឆ្នាំ២០២១

[10] កាសែត Khmer Time ចុះថ្ងៃទី២៣ ខែកក្កដាឆ្នាំ២០២១

[11] កាសែត កម្ពុជាថ្មី ចុះថ្ងៃទី២០ ខែសីហាឆ្នាំ២០២១

## ២.២. បទល្មើសដែលមានលក្ខណៈពិសេស

បទល្មើសដែលមានលក្ខណៈពិសេស ដែលបានលើកយកមកសិក្សាក្នុងពេលនេះមានរូបភាពក្នុងការប្រព្រឹត្តដែលមានលក្ខណៈជាប្រព័ន្ធដោយមានការត្រៀមរៀបចំក្រុមបានត្រឹមត្រូវ មានគម្រោងការច្បាស់នីមួយៗដោយមានការចាត់តាំង រចនាសម្ព័ន្ធ ទៅតាមផ្នែកនីមួយៗដោយនៅក្នុងក្រុមដែលមានការចាត់តាំងនេះមានតួនាទីទៅតាមការរៀបចំ។ ចំពោះបទល្មើសនេះមានលក្ខណៈពិសេសត្រង់ថាបទល្មើសមានលក្ខណៈជាអន្តរជាតិ គឺជាប្រតិបត្តិការចរន្ត លំហូរបទល្មើសពីទីកន្លែងមួយទៅទីកន្លែងមួយទៀតនៅក្នុងគោលបំណងអោយកម្មវត្ថុនៃបទល្មើសមួយកើតឡើងអោយស្របតាមច្បាប់តាមរយៈសកម្មភាពនៃប្រតិបត្តិការ ឬក៏អាចជាការគេចវេសពីការបំពេញកាតព្វកិច្ចដល់កន្លែងណាមួយដែលគេបានកំណត់ជាក់លាក់ នឹងអាចមានរូបភាពពីបទល្មើសផ្ទាល់តែម្តង។[12]

### ២.២.១. បទល្មើសសម្អាតប្រាក់

ការសំអាតប្រាក់ គឺជាសកម្មភាពមួយនៃបទល្មើសដែលបានកើតឡើងក្នុងគោលបំណងដើម្បីអោយផលនៃបទល្មើសដែលបានកើតមុនស្របច្បាប់ទៅតាមមធ្យោបាយដែលបានរៀបចំទុកជាមុន។ ធ្វើអោយប្រាក់នោះអាចយកមកប្រើប្រាស់នៅក្នុងទីផ្សារបានធម្មតាវិញដោយមិនខុសច្បាប់ រួចក៏បង្វិលត្រលប់ទៅរកកន្លែងដើមវិញតាមរយៈរូបភាពជាច្រើនដូចជាការធ្វើជំនួញ ទិញផ្ទះ ដី ឡាន ឬក៏ធ្វើជាជំនួយមនុស្សធម៌ជួយទៅកន្លែងណាមួយដោយលាក់បាំងពីសមាសភាពនៃចរន្តសាច់ប្រាក់។

សកម្មភាពនៃការសំអាតប្រាក់ ចំពោះសកម្មភាពនៃការសំអាតសាច់ប្រាក់នៅក្នុងពេលបច្ចុប្បន្នគឺតាមរយៈរូបភាពជាច្រើនក្នុងនោះមានដូចជាទី១.ការយកប្រាក់ចូលទៅក្នុងប្រទេសណាមួយដោយខុសច្បាប់ ទី២.ជាការផ្ទេរប្រាក់នៅក្នុងចំនួនណាមួយដោយមានការផ្លាស់ប្តូរ ការផ្ទេរពីម្នាក់ទៅម្នាក់ដោយប្រើមធ្យោបាយផ្សេងៗ និងបច្ចេកវិទ្យាការផ្ទេរប្រាក់តាមរយៈធនាគាររេរប្រាក់ធនាគារមួយទៅធនាគារមួយទៀតពីសាខាណាមួយដោយមានបុគ្គលផ្សេងទៀតចាំទទួល។ ចំពោះរូបភាពលើនេះចំណុចដែរ សំខាន់បំផុតនោះគឺមានបុគ្គល ឬក្រុមណាមួយទទួលបន្ត និងជាអ្នកចាំបំប្លែងសាច់ប្រាក់នោះអោយទៅជាប្រាក់ពិតប្រាកដដោយស្របច្បាប់តាមប្រទេសដែលបទល្មើសនោះកំពុងមានសកម្មភាព។[13]

សកម្មភាពមានលក្ខណៈជាក្រុម ចំពោះសកម្មភាពដែលក្រុមនេះបង្កើតឡើងគឺមានលក្ខណៈរចនាសម្ព័ន្ធជាបណ្តាញពីកន្លែងមួយទៅកន្លែងមួយដោយចរន្តលំហូរសាច់ប្រាក់ គឺគ្មានប្រភពច្បាស់លាស់ឡើយ។ ការរៀបចំសកម្មភាពជាក្រុមបែបនេះ គឺមានភាពងាយស្រួលដើម្បីគេចវេសពីច្បាប់ និងអាចលាក់បាំងបាននូវ បទ

---

[12] កាសែត RFI Khmer ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១

[13] កាសែត VOA Khmer ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩

ល្មើសថែមទៀតផង។ ផលវិបាកនៃការសំអាតសាច់ប្រាក់នេះ គឺនៅពេលដែលប្រទេសណាមួយត្រូវបាន ជនល្មើសក្នុងរូបភាពនេះអាចធ្វើទៅបានគឺបានធ្វើឲ្យតម្លៃនៃសេដ្ឋកិច្ចមានការធ្លាក់ចុះតាមបញ្ហាសេដ្ឋកិច្ច បញ្ហា អសន្តិសុខនៅក្នុងសង្គមបទល្មើសជាបានកំពុងតែលេចជារូបរាងឡើង។ ដោយសារចរន្តសាច់ប្រាក់ដែលកើត ចេញពីផលនៃបទល្មើសនេះវាក៏បានដល់ការដឹកនាំ នឹងការគ្រប់គ្រងប្រទេសផងដែរនៅក្នុងក្របខណ្ឌតំបន់ ឫក៏ឆាកអន្តរជាតិដោយសារមូលហេតុថា បទល្មើសនៃការសំអាតប្រាក់ គឺជាកម្មវត្ថុនៃការដោះស្រាយបញ្ហានេះទូទាំងពិភពលោកចូលរួមគ្នាដូច្នេះ បើសិនជាប្រទេសណាមួយអនុញ្ញាតអោយសកម្មភាពបែបនេះហូរចូលមក ដោយសេរីមិនមានវិធានរដ្ឋ និងច្បាប់ទប់ស្កាត់ទេនោះនឹងបង្កដូចដែលបានលើកឡើងខាងលើនេះ។

### ២.២.២. បទល្មើស ហិរញ្ញប្បទានភេរវកម្ម

ជាការពិតណាស់ បទល្មើសនេះមានលក្ខណៈធ្ងន់ធ្ងរបំផុតនៅពេលដែលដំណើរការនៃបទល្មើសទទួលបានលទ្ធផល គឺអាចបង្កនូវព្យសនកម្មដល់សង្គមដោយចរិកគ្រោះថ្នាក់នៃអំពើវាបានបង្កភាពរឹករវនៅក្នុងសង្គមដោយបង្កើតទៅជាបទល្មើសផ្សេងៗគ្នាតាមរយៈការបង្កើតបទល្មើសចេញពីក្រុមតូចៗដែលមានគោលដៅ នឹងគោលបំណងណាមួយតាមដែលអង្គការ ឫអង្គភាពនោះចាត់តាំងអោយអនុវត្តនូវផែនការ។[14] ចំពោះបទល្មើសដែលអាចនឹងកើតមានឡើងតាមរយៈគោលដៅដោយបានរៀបចំនោះអាចមានបទល្មើសដូចជា ការប្លន់ធនាគារ បទល្មើសឃាតកម្ម ការរំលោភសម្លាប់ជាដើម បទល្មើសទាំងនេះហើយគឺបានបង្កព្យសនកម្មទៅដល់ការអភិវឌ្ឍន៍សង្គមជាក់ជាមិនខាន ដោយស្ថានភាពបែបនេះ ក្រុមតូចៗជាអ្នកដើរតួនាទីក្នុងដំណើរការនេះហើយបង្កទៅជាបទល្មើសជាបន្តបន្ទាប់តាមរូបភាពផ្សេងៗគ្នា។

ចំពោះសកម្មភាពនៃប្រតិបត្តិការណ៍នេះដូចគ្នានឹងការសំអាតសាច់ប្រាក់ មានការផ្លាស់ប្តូរពីទីកន្លែងមួយទៅទីកន្លែងមួយដូចគ្នាតែត្រង់ចំណុចពិសេសរបស់បទល្មើស ហិរញ្ញប្បទានភេរវកម្មនេះលទ្ធផលដែលជាផលនៃអំពើគឺសកម្មភាពជួយសម្រួលទៅសកម្មភាពរបស់ក្រុមណាមួយដែលមានគោលដៅ ប្រព្រឹត្តបទល្មើសជាអន្តរជាតិណាមួយ។ អាចនិយាយបានថាគឺការជួយដល់ក្រុមដែលបង្កលក្ខណៈអសន្តិសុខសង្គម និងអន្តរជាតិដែលពិភពលោកកំពុងតែខ្វល់ខ្វាយអំពីបទល្មើសប្រភេទនេះ ប្រសិនបើប្រទេសណាធ្លាក់ចូលក្នុងសភាពការបែបនេះប្រាកដណាស់បទល្មើសនឹងកើតមានភាពអសណ្តាប់ធ្នាប់ក៏កើតឡើង នឹងផ្សេងៗទៀតជាច្រើន។ សកម្មភាពនៃការរៀបចំគឺមានគោលបំណងធំណាមួយតាមការជួយ និងការជ្រោមជ្រែងពីសកម្មភាពនៃក្រុមនោះ។ ដោយមានផែនការមានរចនាសម្ព័ន្ធ ជាក់លាក់ត្រឹមត្រូវនៃក្រមខណ្ឌដូចគ្នាទៅនឹងក្រុមរដ្ឋនៃប្រទេសណាមួយ ប្រសិនបើគម្រោងនោះត្រូវបានបង្កើតឡើងមកពិតប្រាកដ។

[14] ប្រភព៖CROSS CHECK ចុះថ្ងៃទី០២ ខែកក្កដាឆ្នាំ២០២១

សកម្មភាពនៃក្រុមប្រដាប់អាវុធពួកនេះភាគច្រើន គឺជាអ្នកប្រយុទ្ធនៅក្នុងនោះមានការបែងចែកជាក្រុមអ្នកប្រយុទ្ធ ស៊ីឈ្នួលគេ និងមួយទៀតគឺជាក្រុមអ្នកប្រយុទ្ធដើម្បីតស៊ូនឹងរដ្ឋបាលណាមួយជាក់លាក់ដើម្បីគ្រប់គ្រងអំណាចក្រុមពួកគេម្តងវិញ។ អាចនិយាយបានថាការបង្កើតរដ្ឋាភិបាលថ្មីដោយការបង្ហូរឈាមការធ្វើសង្គ្រាមការកាត់សម្លាប់ដោយមិនបានគោរពច្បាប់ជាតិ និងអន្តរជាតិចំពោះទង្វើរបស់ក្រុមនេះមានការថ្កោលទោសខ្លាំងពីសំណាក់អន្តរជាតិ។

# ជំពូកទី២
# ការដាក់ទោស និងការអនុវត្តទោស

# ជំពូកទី២

# ការដាក់ទោស និងការអនុវត្តទោស

នៅក្នុងសង្គមតែងតែមានបញ្ហាកើតឡើង ជាបន្តបន្ទាប់ដោយហេតុការណ៍ខ្លះបានបង្កទៅជាបទល្មើសក្រោយពីពេលដែលមានបទល្មើសមួយបានកើតឡើងបន្ទាប់ពីទទួលបានការស៊ើបអង្កេត និងបានដាក់ទោសទៅលើជនណាមួយហើយគឺដល់ពេលដែលត្រូវមកទទួលនូវទណ្ឌកម្ម ឬការដាក់ទោសដោយធ្វើទៅតាមនីតិវិធីច្បាប់តាមរយៈសេចក្ដីសម្រេចរបស់តុលាការ ត្រូវចាត់ទុកថាជននោះមានទោស ឬក៏គ្មានទោសដោយអង្គហេតុ និងអង្គច្បាប់ផ្អែកតាមការវិនិច្ឆ័យពីភាពត្រឹមត្រូវ យុត្តិធម៌ពិតប្រាកដ។[15] រាល់ជនល្មើសទាំងអស់ដែលបានដាក់ទោសដោយសេចក្ដីសម្រេចរបស់តុលាការស្ថាពរភាពសំខាន់បំផុតនោះគឺថាទោសដែលបានដាក់អោយ បុគ្គលដែលជាទណ្ឌិតអនុវត្តនោះបានត្រឹមត្រូវតាមផ្លូវច្បាប់ឬយ៉ាងណា? នៅពេលដែលបុគ្គលនោះទទួលទោសសាកសមនឹងសកម្មភាពដែលជននោះប្រព្រឹត្តដែរ ឬទេ? ចំពោះការដាក់ទោសនេះអាចអប់រំកែប្រែនៅពេលដែលអនុវត្តទោសរួចហើយបានដល់កម្រិតណា? ជាមួយគ្នានឹងការចូលមករស់នៅក្នុងសង្គមសារជាថ្មីតើបុគ្គលនោះអាចប្រព្រឹត្តបទល្មើសម្ដងទៀត និងសារជាថ្មី ឬទេ? នេះជាបញ្ហា និងមូលហេតុសម្រាប់សង្គមជាតិដែលប្រឈមនៅក្នុងការអនុវត្តច្បាប់សព្វថ្ងៃនៅក្នុងសង្គម។

## ១. ការដាក់ទោសចំពោះបទល្មើស

យន្តការនៃការទទួលខុសត្រូវនូវអំពើដែលខ្លួនបានប្រព្រឹត្ត គឺជាវិធានការផ្អែកច្បាប់មួយដ៏សំខាន់បំផុតនៅក្នុងការបង្កើតច្បាប់ក្នុងក្របខណ្ឌវិស័យយុត្តិធម៌។[16] ជាក់ស្ដែងគេសង្កេតឃើញថាការដាក់ទោសមួយចំនួនក៏មានភាពមិនសូវត្រឹមត្រូវ ឬមិនស្របច្បាប់មួយចំនួនដែរតាមមតិមួយចំនួនដែលបានលើកឡើងទាំងនេះជាសេរីភាពរបស់បុគ្គលនោះតែការអនុវត្តគឺពឹងផ្អែកលើច្បាប់ជាមូលដ្ឋាន បទដ្ឋានគតិយុត្តផ្សេងៗក្នុងការវិនិច្ឆ័យចំពោះបទល្មើសណាមួយត្រូវទទួលកម្រិតណានោះច្បាប់បានបញ្ញត្តិទុក ចំពោះផ្នែកព្រហ្មទណ្ឌ មានបទដ្ឋានគតិយុត្តជាច្រើនដូចជាក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ពិសេស និងដោយឡែកជាច្រើនទៀតដែលមានលក្ខណៈបច្ចេកទេស ជំនាញទៅតាមវិស័យនីមួយៗដែលបានចែងក្នុងសម្រាប់ការអនុវត្តនៅក្នុងសង្គមកម្ពុជា។

មូលដ្ឋាននៃការដាក់ទោសអាចកំណត់បានតាមរយៈប្រភេទនៃបទល្មើសប្រភេទនៃទោសនិងព្យសនកម្មដែលបានបង្កឡើងដោយអនុវត្តផ្អែកលើធាតុផ្សំនៃបទល្មើស ០៣ (បី)សំខាន់មានដូចជាធាតុនីត្យានុកូល (ច្បាប់)

[15] មាត្រា ៦ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[16] មាត្រា ៤ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ធាតុអត្តនោម័ត (ចេតនា ឬអចេតនា) និងធាតុសត្យានុម័ត (សំភារៈ) រាល់បទល្មើសដែលកើតមានឡើងត្រូវតែបំពេញនូវធាតុផ្សំនៃបទល្មើសនេះ។[17]

## ១.១. ការដាក់ទោសចំពោះជនល្មើស

ជនដែលបានប្រព្រឹត្តនូវបទល្មើស គឺត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមានដោយផ្អែកលើការដាក់ទោសតាមច្បាប់ដែលបានចែងទុក និងស្ថានភាពនៃបទល្មើសដែលបានកើតមានឡើងព្យសនកម្មនៃអំពើនោះថាតើបានបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ជនរងគ្រោះ និងសង្គមដល់កំរិតណា។ ជាក់ស្តែងការដាក់ទោសខ្លះអាចមានភាពមិនសូវត្រឹមត្រូវ ឬក៏ខុសលើជនដែលមិនបានប្រព្រឹត្តដោយមានការភាន់ច្រឡំលើចំណុចណាមួយដោយហេតុថាសញ្ញាណនៃបទល្មើសចង្អុលបង្ហាញថាវាពិតប្រាកដតែដល់តាមដានស្រាវជ្រាវបន្តទៀត បែរទៅជាមិនមានភស្តុតាងដាក់បន្ទុកនេះអាចជាកត្តានៃការធ្វេសប្រហែសមួយចំនួនលើការអនុវត្តជាក់ស្តែង។[18]

ស្ថានភាពនៃបទល្មើសមួយចំនួនពេលខ្លះក៏មានការដាក់ទោសមិនសូវជាធ្ងន់ធ្ងរ ឬស្រាលពេកដោយហេតុយល់ឃើញថាបទល្មើសនោះមិនបង្កលក្ខណៈធ្ងន់ពេលនេះ រួមផ្សំជាមួយការអនុវត្តច្បាប់បែបលក្ខណៈមានមនសិការមនុស្សធម៌តែក៏មានបទល្មើសខ្លះអាចបង្កអោយកើតបទល្មើសសារជាថ្មីផងដែរ ប្រសិនបើការដាក់ទោសស្រាលពេក។

ចំពោះការដាក់ទោសលើបុគ្គលណាម្នាក់ ឬក្រុមណាមួយក្នុងនាមជាអ្នកប្រតិបត្តិច្បាប់ អ្នកមានសមត្ថកិច្ចពាក់ព័ន្ធគប្បីត្រូវតែសិក្សាអំពីមូលហេតុនៃការកកើតបទល្មើសស្ថានភាពនៃការប្រព្រឹត្តបទល្មើសអោយ បានល្អិតល្អន់ជាមុនតាមដែរអាចធ្វើទៅបានពីព្រោះថាព្យសនកម្មនៃបទល្មើស ដែលទទួលរងពីការដាក់ទោស អាចនឹងបង្កមកសង្គមវិញប្រសិនបើការសិក្សាមិនបានស៊ីជម្រៅតាមលក្ខណៈវិទ្យាសាស្ត្រនោះទេ។[19]

### ១.១.១. ការដាក់ទោសចំពោះជនដែលប្រព្រឹត្តធ្ងន់ធ្ងរ

ទោះបីជាច្បាប់បានកំណត់ពីទំហំនៃទោស បញ្ញត្តិអំពីអាជ្ញាយុកាលនៃបទល្មើសក៏ដោយផ្អែកលើចរិកគ្រោះថ្នាក់នៃអំពើបុគ្គលដែលបានប្រព្រឹត្តកាលៈទេសៈ និងភាពមិនរាងចាលនៃបទល្មើសត្រូវទទួលទោសអតិបរមាដោយផ្អែកតាម ច្បាប់បានកំណត់ទុក។[20] នៅក្នុងកាលៈទេសៈបែបនេះអាចហៅបានថា ជាផលនៃបទល្មើសដោយការដាក់ ទោសបែបនេះមានន័យថាបុគ្គលនោះ បានប្រព្រឹត្តនូវបទល្មើសមានភាពកាចសាហាវ នឹងទទួលបានទោសខ្ពស់ ស្របតាមច្បាប់គឺជាភាពត្រឹមត្រូវតាមច្បាប់។ តែផលនៃបទល្មើសនៅក្នុងការដាក់ទោសគឺពាក់

[17] មាត្រា ៣ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[18] មាត្រា ២៤ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[19] មាត្រា ២ កថាខណ្ឌទី២ ក្រមនីតិព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[20] មាត្រា ១០ ក្រមនីតិព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ព័ន្ធ នឹងឥទ្ធិពលនៃទោសការដាក់អតិបរមាខ្ពស់វាសាកសមជាមួយសកម្មភាព តែបើសិនជាជននោះមានក្រុមគ្រួសារមានកូនតូចៗ មានឪពុកម្ដាយចាស់ៗ នឹងមានបន្ទុកជាច្រើនទៀតនោះផលនៃបទល្មើសថ្មីមួយនឹងកើតមានឡើង តាមរយៈសេដ្ឋកិច្ចតាមរយៈការមានការមានគំនុំជាដើម។ ទន្ទឹមនឹងនេះដូចគ្នាផងដែរនៅពេលបុគ្គលនោះ ប្រព្រឹត្តបទល្មើសមិនសូវជាមានព្យសនកម្មខ្លាំងដល់ជនរងគ្រោះសង្គមទេតែបែរជាទទួលបានការដាក់ទោសខ្ពស់ដូចគ្នានោះ វាជារឿងមួយដែលត្រូវគិតពិចារណាដោយហេតុថាជននោះប្រាកដជា មានគំនុំក្ដួននៅក្នុងចិត្តនៅពេលណាមួយ ហើយគ្រួសាររបស់ជននោះក៏គិតដូចគ្នាផងដែរ។ ទាក់ទងនឹងការដាក់ទោសខ្ពស់គឺគប្បីពិចារណាទៅលើស្ថានភាពច្បាប់ និងស្ថានភាពសង្គមជាក់ស្ដែងដោយធ្វើសិក្សាអោយបានច្បាស់ពីព្រោះថាផលនៃបទល្មើសវានឹងកើតមានឡើងបន្ទាប់ពីការដាក់ទោស។ ក្នុងន័យនេះមិនមែនមានន័យថាអោយតែការដាក់ទោសខ្ពស់ មិនល្អនោះទេវាក៏មានគុណសម្បត្តិផងចំពោះបទល្មើសមិនឲ្យកើតមានឡើងជាសារថ្មីនៅក្នុងសង្គមទៀត។

### ១.១.២. ការដាក់ទោសចំពោះជនដែលប្រព្រឹត្តស្រាល

ការដាក់ទោសដែលស្រាល ចំពោះជនល្មើសនៅក្នុងសកម្មភាពនៃបទល្មើសមានលក្ខណៈមិនធ្ងន់ធ្ងរវាមិនសូវជាមានបញ្ហានោះទេ។ តែបើសិនជាការប្រព្រឹត្តបទល្មើសនោះមានលក្ខណៈធ្ងន់ធ្ងរហើយការដាក់ទោសបែរជាទៅជាការដាក់ទោសស្រាលចំពោះជននោះវិញអាចបង្កព្យសនកម្មនៅពេលក្រោយដោយបុគ្គលនោះអាចប្រព្រឹត្តបទល្មើសនេះសារជាថ្មី (ការមិនរាងចាល) ចំពោះការគិតរបស់ជនល្មើស។[21]

មួយវិញទៀតគឺការប្រតិកម្មសង្គមដោយសារតែមើលឃើញពីការដាក់ទោសស្រាលដល់ជនល្មើសទាំងនោះអាចបណ្ដាលអោយបុគ្គលផ្សេងទៀតគិតចង់ប្រព្រឹត្តបទល្មើសតាម។

## ១.២. ការអនុវត្តទោស

នៅពេលជនដែលត្រូវបានសេចក្ដីសម្រេចរបស់តុលាការស្ថាពរបុគ្គលដែលជាទណ្ឌិត គឺត្រូវតែនាំទៅអនុវត្តទោសតាមកំរិតទោសដែលបានប្រកាសនោះ។[22] នៅតាមពន្ធនាគារដែលជាកន្លែងមួយអប់រំកែប្រែបុគ្គលនោះឲ្យកសាងខ្លួនអោយល្អដើម្បីគិតពិចារណាចូលទៅរស់នៅក្នុងសង្គមដូចដើមវិញ។[23] ក្នុងពេលដែលកំពុងអនុវត្តទោសគ្រប់បុគ្គលដែលជាទណ្ឌិតត្រូវបានច្បាប់គាំពារជាច្រើនដូចជា៖

---

[21] មាត្រា ៨៣ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[22] មាត្រា ១៧ ច្បាប់ស្ដីពីពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជា

[23] មាត្រា ៦៦ ច្បាប់ស្ដីពីពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជា

### ១.២.១. ការអប់រំ កែប្រែ ទណ្ឌិត

ក្នុងអំឡុងពេលអនុវត្តទោសនៅក្នុងពន្ធនាគារបុគ្គលដែលជាទណ្ឌិតទាំងអស់មានសិទ្ធិ ទទួលបានការអប់រំកែប្រែអោយចូលមករស់នៅក្នុងសង្គមធម្មតាវិញដោយស្របតាមច្បាប់ជាតិ និងអន្តរជាតិ។ ដោយការអប់រំកែប្រែតាមវិធីសាស្ត្ររបស់ពន្ធនាគារតាមរយៈការអប់រំផ្លូវចិត្ត ការធ្វើការងារ មានលំហាត់ប្រាណជាដើម។

ចំពោះបុគ្គលដែលជាទណ្ឌិតណាដែលបានអនុវត្តទោសខិតខំ រៀនសូត្រកែប្រែខ្លួន សកម្មភាពនេះអាចបញ្ជាក់ពីភាពកែប្រែខ្លួនដឹងខុសអំពីអំពើដែលបានប្រព្រឹត្តកន្លងមក នោះបុគ្គលដែលជាទណ្ឌិតអាចទទួលបានការបន្ធូរបន្ថយទោសតាមច្បាប់កំណត់។[24]

### ១.២.២. ការសិក្សាជំនាញផ្សេងៗ

ទន្ទឹមនឹងនេះផងដែរបុគ្គលដែលជាទណ្ឌិតទាំងនោះក៏មានអាចរៀនជំនាញផ្សេងៗណាមួយបាន ដោយមានការបង្ហាត់បង្រៀនការរស់នៅជំនាញក្នុងការប្រកបមុខរបរក្នុងជីវភាពបានធម្មតា ដូចជា កាត់ដេរ ជាងម៉ូតូ ជុសជុលរបស់ផ្សេងៗ និងមានជំនាញជាច្រើនទៀត។

ក្នុងគោលបំណងនៅពេលចេញមកវិញមានចេះដឹង នឹងមានមុខរបរមួយត្រឹមត្រូវលែងប្រព្រឹត្តបទល្មើសឡើងវិញទាំងនេះជាយន្តការមួយចំនួននៅក្នុងពន្ធនាគារ និងច្បាប់ក្នុងការកាត់បន្ថយនូវការប្រព្រឹត្តបទល្មើស។ កត្តាដែលបានអប់រំកែប្រែមានន័យថា បុគ្គលដែលជាទណ្ឌិតបានយល់ច្បាស់នូវកំហុសឆ្គងដែលខ្លួនធ្លាប់បានប្រព្រឹត្តកន្លងមកហើយវាក៏អាចជារឿងល្អមួយផងដែលសម្រាប់ការដឹកនាំសង្គម ប្រកបដោយភាពច្បាស់លាស់ដោយបានយកចិត្តទុកដាក់ចំពោះបុគ្គលដែលជាទណ្ឌិត នេះជាគោលនយោបាយមួយដ៏ឆ្លាសវៃ និងស្របតាមច្បាប់កតិកាសសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិរបស់ជនជាប់ឃុំ និងទណ្ឌិតផងដែរ។

## ២. បទល្មើសកើនឡើង ឬក៏ថយចុះ

បទល្មើសមួយដែលបានកើតឡើងគឺមានមូលហេតុដោយខ្សែកការកើនឡើងនៃបទល្មើស ឬក៏ថយ ចុះនោះមិនប្រាកដមកពីការដាក់ទណ្ឌកម្មទេគឺមានកត្តាជាច្រើនដែលអាចកើតមានឡើងនៅក្នុងនោះក៏មានការដាក់ទណ្ឌកម្មមួយផងដែរ។[25]

ដូចបានលើកឡើងនៅត្រង់ចំណុចខាងលើពាក់ព័ន្ធ ការដាក់ទោសធ្ងន់ ឬស្រាល វាជាកត្តាមួយនៅពេលជននោះវិលត្រលប់ចូលទៅរស់នៅក្នុងសង្គមវិញ ផលនៃបទល្មើសនោះអាចនឹងកើតឡើងហើយវានឹងស្តែងចេញពីភាពស្អប់នៃការដាក់ទោស។ ចំពោះសកម្មភាពរបស់បុគ្គលទាំងនោះអាចកើតចេញពីការតូចចិត្ត ឬការគុំគួន ការស្អប់ខ្ពើម នឹងភាពអយុត្តិធម៌ត្រង់ចំណុចណាមួយមកលើខ្លួនបុគ្គលទាំងនោះ ដោយសារការដែលនៅក្នុង

---

[24] មាត្រា ៦៧ ច្បាប់ស្តីពីពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជា

[25] មាត្រា ៨១ ច្បាប់ស្តីពីពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជា

ពន្ធនាគារមិនទទួលបានការអប់រំកែប្រែបានល្អមានភាពខ្វះខាតនូវការសិក្សារៀនសូត្រ មិនបានរៀនជំនាញ ណាមួយពិតប្រាកដ។ កត្តានេះនៅពេលអនុវត្តទោសចប់បុគ្គលទាំងនោះ មិនដឹងថាខ្លួនអាចធ្វើអ្វីបានស្វែងរកការងារធ្វើកន្លែងមួយចំនួនគេមិនទទួលបុគ្គលដែលធ្លាប់មានប្រវត្តិជាប់ពន្ធនាគារបែបនេះទៀតភាពគ្មានការងារធ្វើ កត្តាសេដ្ឋកិច្ចក្នុងការជីវភាពរស់នៅប្រចាំថ្ងៃ ការមិនយកចិត្តទុកដាក់ពីសង្គមអាចបង្កអោយបុគ្គលទាំងនោះប្រព្រឹត្តនូវបទល្មើសម្តងទៀតក៏អាចថាបានដោយសារតែឥទ្ធិពលសង្គម។[26] ការពិនិត្យគឺអាចមើលឃើញពីការដាក់ទណ្ឌកម្មបានដោយផ្អែកលើសកម្មភាពបទល្មើសការអនុវត្តច្បាប់

**២.១. ការកើនឡើងនៃបទល្មើស**

ចំពោះការកើនឡើងនៃបទល្មើសវាទាក់ទងនឹងច្បាប់ ការអនុវត្ត និងស្ថានភាពសង្គមដែលបទល្មើសនោះកើតឡើងដូចបានរៀបរាប់នៅត្រង់ចំណុចនៃការដាក់ទោសអញ្ចឹងប្រសិនបើមានរូបភាពបែប នេះកើតឡើងប្រាកដណាស់បទល្មើសនឹងមានការកើនឡើងជាបន្តបន្ទាប់ដោយហេតុថាវាអាច អោយមានភាពស៊ាំនឹងទង្វើសកម្មភាពរបស់បុគ្គលទាំងនោះដោយការមិនគោរពច្បាប់ និងស្ថានភាពមិនរាងចាលជាដើម។

**២.២.១. ការមិនរាងចាល**

ជាកត្តាមួយក្នុងការកើនឡើងនូវបទល្មើសដោយភាពបំពានមិនខ្លាចដោយសារតែ ការដាក់ទោសស្រាលពេកគ្មានអ្នកណារារាំងនូវសកម្មភាពទង្វើរបស់បុគ្គលទាំងនោះដូច្នេះជាហេតុបង្កអោយមានបទល្មើស កើនឡើងតាមរយៈស្ថានភាពបែបនេះ។[27]

ស្ថានភាពនៅក្នុងការអនុវត្តច្បាប់មិនសូវទទួលបានលទ្ធផលល្អដោយសារបញ្ហា ក្នុងកំរិតនៃការអនុវត្តអំណាចដែលនៅពីក្រោយនៃអនុវត្តច្បាប់ និងអ្នកអនុវត្តច្បាប់មិនសូវមានចំណេះគ្រប់គ្រាន់ ឬពុំសូវមានបទពិសោធន៍ និងចំណេះដឹងនៅមានកំរិត។ កត្តាទាំងនេះក៏ជាមូលហេតុផងដែរទោះបីជាច្បាប់ល្អត្រឹមត្រូវយ៉ាងណាក៏ដោយបើការអនុវត្តដូចដែលបានលើកឡើងនេះកំរិតនៃបទល្មើសការមិនរាងចាលបទល្មើស នៅតែបន្តកើតមានឡើងវាបានបង្កព្យសនកម្មយ៉ាងសកម្មក្នុងដំណើរការនៃការអភិវឌ្ឍន៍សង្គមជាតិយើងនាពេលខាងមុខ។

**២.២.២. កាលៈទេសៈ នៃបទល្មើស**

ស្ថានភាពមួយចំនួនអាចកើតឡើងដោយសារតែការមិនប្រុងប្រយ័ត្ន ការធ្វេសប្រហែសជាដើម។ នេះក៏ជាមូលហេតុនៃការកើនឡើងបទល្មើសថ្មីមួយផងដែរអាចជាសកម្មភាពដែលបទល្មើសបង្កលក្ខណៈងាយស្រួលដល់អ្នកប្រព្រឹត្តចំពោះបទល្មើសមួយចំនួនដែលបានកើតឡើងដោយកាលៈទេសៈមូលហេតុអាចបណ្តាលមកពីកត្តានៃជនរងគ្រោះខ្លួនឯងផ្ទាល់ និងមជ្ឈដ្ឋាននៅជុំវិញខ្លួន។

---

[26] មាត្រា ៦៧ ច្បាប់ស្តីពីពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជា

[27] មាត្រា ៨៣ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

កត្តានៃជនរងគ្រោះខ្លួនឯងផ្ទាល់ត្រង់នេះសំដៅទៅលើការមិនបានប្រុងប្រយ័ត្ន និងត្រៀមលក្ខណៈដល់ខ្លួនឯងដូចជាការបង្ហាញនូវរបស់របរមានតម្លៃ ប្រាក់ មាស ពេជ្រ តាមរយៈសកម្មភាពណាមួយនៅពេលនោះ បទល្មើសគឺបានចាប់ផ្តើមមានដោយសារការបង្ហាញធ្វើអោយចោរអាចដឹង និងរងចាំពេលវេលាសមស្របនឹងលួចយកនេះហើយដែលបណ្តាលមកពីកត្តាខ្លួនឯង។ មួយទៀតបទល្មើសរំលោភសេពសន្ថវៈការស្លៀកពាក់ខ្លីរបស់មនុស្សស្រី ដែលបង្ហាញចេញនូវសាច់សករណីបែបនេះក៏បណ្តាលឲ្យបង្កលក្ខណៈងាយស្រួលដល់បទល្មើសផងដែរ។

## ២.២. ភាពថយចុះនៃបទល្មើស

កត្តាដែលថយចុះនៃបទល្មើសមានកត្តាជាច្រើនដូចជា កត្តាច្បាប់ ការអនុវត្តច្បាប់ យល់ដឹងអំពីច្បាប់ពីសំណាក់ប្រជាពលរដ្ឋ កត្តាសេដ្ឋសេដ្ឋកិច្ចជាដើម។ ការថយចុះនៃបទល្មើសភាគច្រើននាពេលបច្ចុប្បន្នដោយសារតែមានការចេះយោគយល់គ្នាទៅវិញទៅមកក្នុងជីវភាពក្នុងការរស់នៅ ការចែករំលែកនូវបទពិសោធន៍ចំណេះដឹងយើងអាចស្រមៃបានថានាពេលខាងមុខនៅពេលដែលប្រជាជនយើងមាន ចំណេះដឹងយល់ច្បាស់សិទ្ធិច្បាប់ការគោរពគ្នាបទល្មើសចរាចរណ៍នៅក្នុងប្រទេសយើង នឹងមានភាពកាត់បន្ថយកាន់តែខ្លាំងឡើងៗជាមួយឆ្នាំមួយឆ្នាំនេះជារឿងពិតដែលយើងរាល់គ្នាអាចឈ្វេងយល់បាន។

### ២.២.១. ការអនុវត្តច្បាប់បានល្អ

នៅពេលដែលមានភាពត្រឹមត្រូវមានច្បាប់មួយដ៏រឹងមាំគួបផ្សំជាមួយការអនុវត្តបានប្រសើរ នោះបទល្មើសពុំសូវកើតមានឡើយជាការពិតជនល្មើសមានការខ្លាចរអានូវទង្វើដែលខ្លួនបានធ្វើ ដោយសារតែមានច្បាប់ពិតដាក់ទោសការអនុវត្តល្អ។

### ២.២.២. ការអប់រំ កែប្រែ មានប្រសិទ្ធភាព

ការអប់រំកែប្រែបានល្អមានប្រសិទ្ធភាពនៅក្នុងពេលអនុវត្តទោសមានការបង្ហាត់ បង្រៀនជំនាញមានសកម្មភាពសហគមន៍មានការជួយគ្នាការលើទឹកចិត្តការព្យាបាលរបបអាហារល្អអប់រំអោយចេះស្រលាញ់ គ្រួសារខ្លួនឯងស្គាល់ច្បាស់ពីតម្លៃសង្គម។ នេះហើយបទល្មើសប្រាកដជាមាន ការថយចុះ នឹងមានភាពល្អប្រសើរឡើងដោយសារកត្តានេះជាពិសេសគឺបុគ្គលទាំងនោះចេះកែប្រែចេញពីទឹកចិត្តមានស្មារតីល្អ ច្បាប់ការអនុវត្តពិតជាសំខាន់ណាស់នៅក្នុងការចូលរួមកាត់បន្ថយការកើនឡើងនៃបទល្មើសនៅក្នុងសង្គម ។[28]

[28] មាត្រា ៦៦,៦៧ ច្បាប់ស្តីពីពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី៣
# មូលហេតុនៃការកកើតបទល្មើស
# នៅក្នុងសង្គម

# ជំពូកទី៣
# មូលហេតុនៃការកើតបទល្មើសនៅក្នុងសង្គម

ចំពោះបទល្មើសជាបាតុភូតរបស់សង្គមជាផលរបស់ដែលកើតចេញពីសង្គម។ ដូចនេះមូលហេតុ និងលក្ខខណ្ឌនៃបទល្មើសគឺបណ្តាលឥទ្ធិពលសរុបដំណើរការរបស់សង្គមជាកត្តាកំណត់អោយមានបទល្មើស ដែលជាផលិតផលរបស់វា។ នោះគឺជាបណ្តាបាតុភូតដំណើការសង្គមសរុប ដែលបង្កអោយមានបទល្មើស។ បទល្មើសត្រូវបានកំណត់ដោយស្ថានភាពបទល្មើសជាក់ស្តែងដែលបានកើតឡើងនៅក្នុងអំឡុងពេល និងលំហាណាមួយជាកំណត់។ ហេតុនេះមូលហេតុ និងលក្ខខណ្ឌនៃបទល្មើសក៏ត្រូវបានពិនិត្យស្រាវជ្រាវនៅក្នុងលំហនិងពេលវេលាជាកំណត់ដូចគ្នាផងដែរ។ មូលហេតុ និងលក្ខខណ្ឌនៃបទល្មើសផ្សារភ្ជាប់ជាមួយព្រឹត្តការណ៍នយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ និងមនុស្សនៅតាមដំណាក់កាលនៃប្រវត្តិសាស្ត្រ។ មូលហេតុ និងលក្ខខណ្ឌនៃបទល្មើសតែងតែមានការផ្លាស់ប្តូរប្រែប្រួលទៅតាមស្ថានភាពរបស់សង្គមដែលមានការវិវឌ្ឍន៍ជានិច្ច។

ដោយហេតុថាបទល្មើសជាផល (បច្ច័យ) នៃដំណើរប្រែប្រួល និងអសកម្មរបស់សង្គមនោះមូលហេតុ និងលក្ខខណ្ឌគឺជាបណ្តាព្រឹត្តហេតុសង្គមដែលបង្កអោយមានបទល្មើសដោយផ្ទាល់។ ដូចនេះបើគិតពេលវេលានោះមូលហេតុ និងលក្ខខណ្ឌនៃបទល្មើសត្រូវកើតមានមុនបទល្មើស។ មូលហេតុនៃបទល្មើស គឺជាបណ្តាសរុបនៃដំណើការសង្គមដែលបានបង្កឡើងនូវបទល្មើសដោយផ្ទាល់។ ឯលក្ខខណ្ឌនៃបទល្មើសគឺជាបណ្តាឥទ្ធិពលនៃដំណើរការសង្គមដែលបង្កអោយមានភាពអំណោយផលសំរាប់ភាពគង់វង្សនៃបទល្មើស។ មូលហេតុ និងលក្ខខណ្ឌនៃបទល្មើសមិនស្ថិតស្ថេរគង់វង្សជានិរន្តន៍ឡើយវាតែងតែផ្លាស់ប្តូរគ្នា ឬមួយត្រូវវិនាសបាត់បង់អាស្រ័យដោយកត្តាសកម្មភាពរបស់សង្គមដូចនេះការប្រឆាំងលុបបំបាត់ បទល្មើសជាតុពិតគឺការតស៊ូលុបបំបាត់ចោលនូវមូលហេតុ និងលក្ខខណ្ឌនៃបទល្មើស។ មូលហេតុ និងលក្ខខណ្ឌនៃបទល្មើសត្រូវបានបែងចែកជាមូលហេតុនៃបទល្មើសនៅក្នុងមជ្ឈដ្ឋាន និងមូលហេតុលក្ខខណ្ឌនៃបទល្មើសជាក់ស្តែង។[29]

នៅក្នុងសង្គមកត្តាដែលបណ្តាល ឬបង្កឲ្យកើតជាបទល្មើសមានច្រើនរូបភាព និងផ្សេងៗពីគ្នាទៅតាមប្រភេទនៃបទល្មើសនីមួយៗជាពិសេសទាក់ទងទៅនឹងកំរិតគ្រោះថ្នាក់នៃបទល្មើសរួមជាមួយព្យសនកម្មដែលទទួលរង និងផលនៃបទល្មើសនោះផងដែរ។ ជាក់ស្តែងនៅក្នុងសង្គមឃើញមានរូបភាពនូវបទល្មើសជាដូចខាងក្រោមៈ

[29] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

## ១. បណ្តាលមកពីវប្បធម៌ការអប់រំ និងច្បាប់

ជាការពិតណាស់ពាក់ព័ន្ធ ទៅនឹងវប្បធម៌ការអប់រំ និងច្បាប់ នៅក្នុងសង្គមណាក៏ដោយ គឺមានភាពចាំបាច់បំផុតក្នុងការដឹកនាំសង្គមនោះឲ្យមានភាពល្អប្រសើរឡើង។ ទន្ទឹមគ្នានោះផងដែរកត្តាទាំងនេះក៏អាចជះឥទ្ធិពលទៅដល់ការដឹកនាំផងដែរ ប្រសិនបើវប្បធម៌បានហូរចូលមកដោយមិនមានភាពត្រឹមត្រូវ ជាពិសេសគឺការអប់រំរបស់នៅមានកម្រិតដូចនេះ ធ្វើឲ្យការទទួលយកនូវវប្បធម៌ណាមួយមកប្រើប្រាស់ អាចបង្កជាបទល្មើសជាដើម។ ដូច្នេះត្រូវបង្កើតច្បាប់ដើម្បីទប់ស្កាត់ការហូរចូលវប្បធម៌មិនល្អ និងផ្សព្វផ្សាយឲ្យបានទូលំទូលាយពីគុណសម្បត្តិ ភាពប៉ះពាល់អោយបានច្រើន។

### ១.១. កត្តាវប្បធម៌ និងការអប់រំ

ប្រទេសជាតិមួយរីកចម្រើនអភិវឌ្ឍន៍ទៅមុខបានល្អដោយសារតែមានកត្តានៃការអប់រំ និងវប្បធម៌នេះគឺអាចសង្កេតបានថាការអប់រំដល់កម្រិតណាដូចគ្នាផងដែរទាក់ទងទៅនឹងវប្បធម៌ សីលធម៌សង្គម។ វប្បធម៌ និងការអប់រំវាជាផ្នែកមួយនៃការកកើតជាបទល្មើស ដោយសារមានសណ្ឋាននៃការរស់នៅមានភាពប្លែកៗពីគ្នាតួយ៉ាងយើងអាចសង្កេតអំពីការរស់នៅរបស់ប្រជាជននៅតាមបណ្តាលប្រទេសនៅលោកខាងលិច។ ភាគច្រើនមិនដូចការរស់នៅក្នុងប្រទេសឡើយចំពោះវប្បធម៌ និងការអប់រំ មានភាពមិនដូចគ្នាត្រង់ថាវប្បធម៌កម្ពុជាមានភាពល្អប្រពៃដោយការជួបគ្នាតែងតែសំពះគ្នាទៅវិញទៅមក សម្រាប់ជនបរទេសគឺមានការចាប់ដៃ ឬថើបគ្នា នេះបានបង្ហាញនូវវប្បធម៌មួយដែលជះឥទ្ធិពលមកវប្បធម៌នៃការរស់នៅរបស់ប្រទេសយើង។ ដោយឡែកការអប់រំវិញការជឿនលឿនទៅមុខរបស់ប្រទេសលោកខាងលិចជាដើម គឺគេបានដើរមុនយើងដូច្នេះស្តង់ដារការអប់រំក៏មានលក្ខណៈខុសគ្នាផងដែរ។ ចំពោះការអប់រំមានការទទួលស្គាល់នៅទូទាំងពិភពលោកទាំងការបង្រៀនតាមបែបទំនើបរបស់លោកខាងលិច ភាពរីកចម្រើនការអប់រំបានធ្វើអោយប្រជាពលរដ្ឋនៅក្នុងប្រទេសនោះមានការយល់ដឹងអំពីច្បាប់ មានការចេះយោគយល់គ្នា។[30]

#### ១.១.១. កត្តាវប្បធម៌

ជាបាតុភូតដែលមានលក្ខណៈ លំបាកនៅក្នុងទ្រឹស្តីទិដ្ឋភាពអប់រំសំដៅទៅលើសតិសម្បជញ្ញៈរបស់បុគ្គលកំរិតវប្បធម៌ សាសនា សិល្បៈ ពូជពង្ស នីតិ បទដ្ឋានរដ្ឋ មនោគមវិជ្ជា ចិត្តសាស្ត្រ ។ល។ ប្រជាជនណាក៏ដោយក៏មានមោទនភាពចំពោះវប្បធម៌ និងអរិយធម៌របស់ខ្លួនហើយម្យ៉ាងទៀតក៏ពុំមែនបដិសេធចំពោះបណ្តាលវប្បធម៌របស់ប្រជាជាតិផ្សេងដែលមានលក្ខណៈល្អប្រសើរដែលកំពុងហូរចូលហើយកំពុងមានឥទ្ធិពលមកលើ និងលាយឡំនៅក្នុងវប្បធម៌របស់ប្រជាជាតិមួយនោះផងទេ។

[30] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

ប៉ុន្តែប្រការមួយដែលគប្បីនឹងត្រូវពិចារណា គឺលំហូរចូលនូវវប្បធម៌មួយចំនួនដែលបង្កអោយមានអសកម្ម ដល់សង្គមដូចជាការសម្លាប់មនុស្សរំលោភសេពសន្ថវៈ ប្លន់ធនគារ ប្លន់ទ្រង់ ទ្រាយធំដែលមួយចំនួននៃករណី នេះត្រូវបានផ្តើមចេញពីការទស្សនាភាពយន្តដែលមានសកម្មភាពឃោឃៅដែលមានភាពជំរុញ អារម្មណ៍ ផ្នែក ផ្លូវកាមរបស់ជនបរទេស។ មូលហេតុដែលកើតចេញពីលំហូរចូលនូវវប្បធម៌ហើយអាចបង្កទៅជាបទល្មើសកើត ឡើងនៅក្នុងសង្គមតាមរយៈរូបភាពខាងលើ។

**១.១.២. កត្តាការអប់រំ**

ការអប់រំ គឺជាកត្តាសំខាន់បំផុតនៅក្នុងការដឹកនាំសង្គមជាតិមួយអោយមានភាពរីកចម្រើនទៅមុខ និង ជៀសឆ្ងាយពីបទល្មើសមួយចំនួនបានដែរដោយសារប្រជាពលរដ្ឋមានចំណេះដឹងគ្រប់គ្រាន់។ដោយឡែកគ្រួសារ សាលារៀន និងមជ្ឈដ្ឋានសង្គមមានតួនាទីរួមគ្នាក្នុងការអប់រំមនុស្សដែលជាសមាជិករបស់សង្គមជាតិ។ ភាព អវិជ្ជាសីលធម៌រស់នៅមិនសមរម្យជាផលដែលបានកើតចេញមកពីកង្វះការអប់រំបានបង្កអោយមនុស្សមួយចំនួន ធ្លាក់ចូលទៅក្នុងផ្លូវប្រព្រឹត្តបទល្មើស។[31]

ទោះបីមានទ្រឹស្តីរបស់អ្នកប្រាជ្ញា មួយចំនួនបានទទួលស្គាល់នូវនិស្ស័យរបស់មនុស្សដែលមានពីកំណើត ប៉ុន្តែទ្រឹស្តីទាំងនោះមិនបានបដិសេធនូវការអប់រំដែលជាការកំណត់នូវសកម្មភាព អត្តចរិត របស់មនុស្សឡើយ។ មជ្ឈដ្ឋានជុំវិញខ្លួនមនុស្សបានធ្វើអោយមនុស្សមានការរីកចម្រើន លូតលាស់ និងធ្វើការសម្រេចចិត្តក្នុងសកម្ម ភាពប្រចាំថ្ងៃរបស់ខ្លួនដូចនេះកត្តាអប់រំអាចក្លាយជាមូលហេតុ និងលក្ខខណ្ឌចំបងមួយក្នុងចំណោមនិងមូល ហេតុផ្សេងទៀតនៃការកើតបទល្មើស។ ប្រសិនបើជនទាំងនោះមិនទទួលបាននៃការអប់រំទេ មូលហេតុដែលបង្ក អោយកើតបទល្មើសមានដូចជាការលួច ឆក់ ប្លន់ ការសម្លាប់មនុស្សជាដើម នឹងកើតមានជាច្រើនឡើងនៅក្នុង សង្គមនោះ។

**១.២. កត្តាច្បាប់ និងការផ្សព្វផ្សាយ**

ការកសាងនីតិរដ្ឋត្រូវបានលើកឡើងដោយគ្រប់ប្រជាជាតិរួមជាមួយកម្ពុជាផងដែលហើយចាត់ទុកថាជា បញ្ហាចំបង និងសំខាន់សំរាប់គ្រប់គ្រងសង្គមនិងដោយឡែកចំពោះការងារតស៊ូប្រឆាំងនិងបង្ការបទល្មើស។ នៅ ក្នុងនីតិរដ្ឋរាល់សកម្មភាពរបស់ស្ថាប័នរដ្ឋ សង្គមរួមទាំងពលរដ្ឋផងមានភាពសកម្ម និងឯកភាពគ្នាក្នុងការលុប បំបាត់ចោលនូវបាតុភូតអសកម្មនានាដែលជាមូលដ្ឋាននៃភាពស្ថិតស្ថេរ និងរីកចម្រើននៃបទល្មើសដែលកំពុងតែ កើតមានឡើងនិងត្រៀមកើតមានឡើងនាពេលអនាគត។ ការកសាងច្បាប់មួយអោយបានល្អដោយ មានភាព សមភាពត្រឹមត្រូវមានន័យថាសង្គមនោះបានរីកចម្រើន និងបង្កាបទល្មើសរួចទៅហើយជាគ្នានេះផង។ ការបង្កើត

[31] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

ច្បាប់បានហើយត្រូវតែមានការផ្សព្វផ្សាយ និងមានការចែករំលែកអំពីការអនុវត្តមានការផ្សព្វផ្សាយដល់ប្រជាជនអោយមានដឹងលឺ និងស្វែងយល់ពីអត្ថន័យគោលបំណងរបស់ច្បាប់ដែលបង្កើតឡើងមកនោះការផ្សព្វផ្សាយច្បាប់ប្រៀបបានដូចជាការលុបបំបាត់នូវបទល្មើសដែលកំពុងតែរៀបនឹងកើតឡើង។[32]

### ១.២.១. កត្តាច្បាប់

ច្បាប់គឺជាបញ្ញត្តិមួយដែលបានចងក្រងឡើងនៅក្នុងគោលបំណង ដើម្បីធានានូវផលប្រយោជន៍ណាមួយដែលកើតឡើងនៅក្នុងសង្គមទាំងស្ថេរភាពសន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសង្គមជាដើម ការប្រឆាំង និងបង្កាបទល្មើសតែងតែផ្សារភ្ជាប់ការទាមទារអោយមានការគាំទ្រដោយកម្លាំងបង្ខិតបង្ខំរបស់ច្បាប់។ម្យ៉ាងទៀតពលរដ្ឋអាចកំណត់បាននូវទិសដៅសកម្មភាពត្រឹមត្រូវរបស់ខ្លួនក្នុងជីវភាពសង្គមបាន អាស្រ័យដោយមូលដ្ឋាននៃការកំណត់របស់ច្បាប់។ ភាពខ្វះខាតភាពអន់ថយការប្រទាំងប្រទើសគ្នានៃច្បាប់នាំមកនូវភាពច្របូកច្របល់ក្នុងការកំណត់ និងវិនិច្ឆ័យអំពីបទល្មើសដែលកើតមានក្នុងសង្គម។

ការរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយសន្តិសុខសង្គមដោយច្បាប់គឺជាស្ថានភាពបន្ទាប់សំរាប់នីតិរដ្ឋហើយជាពិសេសក្នុងវិស័យតស៊ូប្រឆាំង និងបង្កាបទល្មើស។ ផ្ទុយទៅវិញភាពចន្លោះប្រហោងឬភាពអន់ថយ និងកង្វះខាតនៃច្បាប់ នឹងមានឥទ្ធិពលធ្វើអោយបញ្ហាបទល្មើសឈានឡើងដល់កំរិតធ្ងន់ធ្ងរសម្រាប់សង្គមជាតិទាំងមូល។ ដូច្នេះត្រូវមានច្បាប់ក្នុងការបង្កា នឹងទប់ស្កាត់នូវបទល្មើសកុំអោយកើតមានឡើងប្រសិនបើមិនដូចនេះទេវានឹងមានបទល្មើសកើតឡើង នឹងសង្គមជួបវិបត្តិនេះជាក់ជាមិនខាន។

### ១.២.២. កត្តាការផ្សព្វផ្សាយច្បាប់

ការមិនយល់ដឹងអំពីច្បាប់ជាមូលដ្ឋានមួយដែលនាំអោយមានការប្រព្រឹត្តបទល្មើសពីសំណាក់ ជនមួយចំនួនដែលជាប្រការមួយគួរអោយសោកស្តាយ។ ជាធម្មតាមនុស្សចូលរួមនៅក្នុងទំនាក់ទំនងសង្គម លើគ្រប់វិស័យក្នុងគោលបំណងបំពេញនូវសេចក្តីត្រូវការទាំងផ្នែកសេដ្ឋកិច្ចប្រយោជន៍ជាសម្ភារៈ ស្មារតី ប៉ុន្តែសកម្មភាពរបស់មនុស្សអាចបំពានទៅលើផលប្រយោជន៍សង្គម ឬផលប្រយោជន៍របស់បុគ្គលដទៃទៀតដែលក្នុងនោះបណ្តាលមកពីមូលហេតុនៃការយល់ដឹងអំពីការទាមទាររបស់សង្គមជាពិសេសការទាមទាររបស់ច្បាប់ ដែលបានកំណត់អំពីវិធីធ្វើសកម្មភាព ឬហាមឃាត់នូវសកម្មភាពមួយចំនួនជាកំណត់ដែលបង្កអោយមានការអន្តរាយដល់ផលប្រយោជន៍ ឬទំនាក់ទំនងសង្គម។

ប្រព័ន្ធច្បាប់មានលក្ខណៈសុក្រិតស្របតាមស្ថានភាពសង្គមនឹងក្លាយទៅជាគ្មានតម្លៃ គ្មានប្រយោជន៍ប្រសិនបើខ្លឹមសារនៃច្បាប់នោះជ្រាបចូលទៅក្នុងមនសិការរបស់ពលរដ្ឋហើយជាការពិត មិនមានមនសិការច្បាប់

[32] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

ចំពោះពលរដ្ឋឡើយប្រសិនបើច្បាប់ទាំងនោះមិនត្រូវបានផ្សព្វផ្សាយអោយទូលំទូលាយទៅដល់ប្រជាជននោះទេ ការបង្កើតច្បាប់ឡើងក៏មិនមានប្រសិទ្ធភាពក្នុងការអនុវត្តឡើយ។ ពលរដ្ឋអាចធ្វើ ឬមិនធ្វើនូវសកម្មភាពណាមួយ ដែលបង្កអោយមានការអន្តរាយដល់សង្គម នៅពេលដែលគេមានការយល់ដឹងអំពីការទាមទាររបស់សង្គមដែល ត្រូវបានស្តែងឡើងតាមរយៈបទបញ្ញត្តិនៃច្បាប់។ នៅបណ្តាលប្រទេសខ្លះ នៅក្នុងអំឡុងពេលណាមួយនោះបញ្ហា នៃបទល្មើសបានឈានឡើងដល់កំរិតធ្ងន់ធ្ងរហើយសឹងតែមិនអាចគ្រប់គ្រងបាន ដែលជាហេតុបណ្តាលអោយ មានការអន្តរាយធ្ងន់ធ្ងរ និងប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពលរដ្ឋទាំងផ្នែកសេដ្ឋកិច្ច និងសុវត្ថភាពឯកជន។ មានករណីខ្លះបទល្មើសបានកើតឡើងនៅទីប្រជុំជន នៅចំពោះមុខមន្ត្រីមានសមត្ថកិច្ច ទំហំនៃការអន្តរាយធ្ងន់ធ្ងរ ហើយពេលខ្លះមានទិសដៅប្រឆាំងនឹងមនុស្សទូទៅ។ ភាពគង់វង្សនូវស្ថានភាពនេះមួយផ្នែកគឺអាស្រ័យដោយ កង្វះសមត្ថភាពរបស់ស្ថាប័នការពារច្បាប់កង្វះការសហការរវាងស្ថាប័នទាំងនោះ និងកង្វះភាពប្តូរផ្តាច់ក្នុងការ ប្រឆាំងនឹងបទល្មើស ដែលជាហេតុនាំអោយមានការមើលស្រាលច្បាប់ពីសំណាក់ជនល្មើសរួមទាំងការមើល ស្រាលចំពោះស្ថាប័នការពារច្បាប់ផងដែរ។

មូលហេតុផ្សេងទៀតគឺកង្វះមធ្យោបាយប្រឆាំងបង្កាបទល្មើសដែលមានលក្ខណៈ គ្រប់ជ្រុងជ្រោយនិង មានលក្ខណៈវិទ្យាសាស្ត្រ។ ប្រការនេះនាំមកនូវភាពអសកម្មក្នុងការបង្ក្រាបបទល្មើសដែលកើតមានលើគ្រប់វិស័យនៃ សង្គមពោលគឺការធ្វើសកម្មភាពប្រឆាំងបទល្មើសនៅក្នុងវិស័យណាមួយជាកំណត់ នៅពេលដែលបញ្ហាមូល ហេតុបទល្មើសនៃវិស័យទាំងនោះបានឈានឡើងដល់កំរិតធ្ងន់ធ្ងរ ឯបញ្ហាការកកើតបទល្មើសដែលបានកើត ឡើងនៅក្នុងវិស័យផ្សេងទៀតហើយកំពុងតែមានសន្ទុស្សន៍កើនឡើង តែមិនទាន់ដល់កម្រិតធ្ងន់ធ្ងរបែរជាមិនសូវ អើពើទៅវិញ។ ការតស៊ូប្រឆាំង និងបង្កាបទល្មើសទាមទារអោយមានផែនការសកម្មភាពដែលបានព្យាករណ៍ទុក មុនប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ។ បញ្ហាជាមូលដ្ឋានគឺការកំណត់នូវមូលហេតុ និងលក្ខខណ្ឌដែលនាំមក នូវបទល្មើសវាមិនមែនជាការរត់តាមមូលហេតុនិងលក្ខខណ្ឌដែលបង្កអោយមានភាពគង់វង្សរីកចម្រើននៃបទល្មើស។

សកម្មភាពរបស់ស្ថាប័នការពារច្បាប់ ចំណុះក្រោមសកម្មភាពរបស់មន្ត្រីនៅក្នុងស្ថាប័ននោះ។ លទ្ធផល នៃសកម្មភាព ស៊ើបអង្កេត ចោទប្រកាន់ ជំនុំជំរះ អប់រំកែប្រែទណ្ឌិតទទួលបានលទ្ធផលគាប់ប្រសើរ អាស្រ័យ ដោយសកម្មភាពសីលធម៌ ភាពប្តូរផ្តាច់ជំនឿជឿជាក់របស់មន្ត្រីមានសមត្ថកិច្ចនៅក្នុងកិច្ចការនោះ។ ប្រសិនបើពុំ បានយកចិត្តទុកដាក់ចំពោះបញ្ហាខាងលើនោះការងារប្រឆាំង និងបង្កាបទល្មើសនឹងជួបប្រទះនូវឧបសគ្គជាក់ជា មិនខានឡើយ។[33]

---

[33] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន វិទ្ធ)

## ២. មជ្ឈដ្ឋាន នៃការរស់នៅរបស់បុគ្គល

ទីតាំងភូមិសាស្ត្រមានឥទ្ធិពលផងដែរដល់បញ្ហានៃបទល្មើស។ រវាងទីក្រុង ជនបទតំបន់ព្រៃភ្នំវាល ទំនាបស្ថានភាពនៃបទល្មើសមានលក្ខណៈ និងការវិវឌ្ឍន៍ខុសគ្នាបទល្មើសមួយចំនួនអាចកើតឡើងអាស្រ័យ ដោយស្ថានភាពនៃទីតាំងភូមិសាស្ត្រដូចជាការកាប់ព្រៃខុសច្បាប់អាចកើតឡើង នៅតែតំបន់មានព្រៃឈើបទ ល្មើសនេសាទអាចកើតឡើងមានតែនៅតំបន់ដែលមានទន្លេ បឹង ស្ទឹង ព្រែក ការកកស្ទះចរាចរដែលកើតមាន នៅទីក្រុងដែលនាំអោយមានភាព តានតឹងអារម្មណ៍ដែលអាចជាមូលហេតុនាំអោយមានគ្រោះថ្នាក់ចរាចរណ៍ទី កន្លែងស្ងាត់ជាកាលៈទេសៈគាប់ប្រសើរសំរាប់ការប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈជាដើម។

### ២.១. ស្ថានភាពភូមិសាស្ត្រនៃការរស់នៅ

កត្តាអសកម្ម នៅក្នុងមជ្ឈដ្ឋានរស់នៅមានឥទ្ធិពលដល់ការផ្លាស់ប្តូរនូវទស្សនៈរបស់បុគ្គលហើយជា ទូទៅវាស្តែងឡើងនៅក្នុងរចនាសម្ព័ន្ធនៃបទល្មើស។ ម្យ៉ាងវិញទៀតទំនាក់ទំនងមិនស្របគ្នារវាងបុគ្គលនិងសង្គម រវាងការទាមទាររបស់សង្គម និងតម្រូវការរបស់បុគ្គលក៏ត្រូវបានស្តែងឡើងនៅក្នុងរចនាសម្ព័ន្ធនៃបទល្មើសផងដែរ។ ទំនាស់រវាងផលប្រយោជន៍ការទាមទាររបស់សង្គម និងផលប្រយោជន៍របស់បុគ្គលបានបង្កអោយមានការកកើត និងពង្រឹងនូវមូលហេតុនៃបទល្មើសហើយដែលជាមូលហេតុដោយឡែកនៃការប្រព្រឹត្តបទល្មើស។[34]

នៅក្នុងឧក្រិដ្ឋវិទ្យា គេបែងចែកមូលហេតុនៃបទល្មើសជាៈ

- មូលហេតុនយោបាយ (ការប្រឆាំងនឹងរបបគ្រប់គ្រង នយោបាយ សាសនា ជនជាតិ... )
- មូលហេតុ ប្រយោជន៍ផ្ទាល់ខ្លួន
- មូលហេតុទំនាក់ទំនងរវាងបុគ្គល និងបុគ្គល (ស្អប់ គំនុំ សងសឹក...)
- មូលហេតុបុគ្គល (អត្តចរិក) ដូចជាការមើលស្រាលចំពោះកាតព្វកិច្ច មុខងារ គ្រួសារ...។

អត្តចរិកឯកជន (បុគ្គលិកលក្ខណៈ) នៃជនល្មើសត្រូវបានកើតឡើងនៅក្នុងមជ្ឈដ្ឋានគ្រួសារ គឺជាប្រភពនៃកំណ កំណើតមនុស្សជាទីកន្លែងកសាងនូវ អត្តចរិករបស់មនុស្ស និងការកំណត់អំពីទិសដៅគោលដៅនៃសកម្មភាព របស់មនុស្សតាំងពីវ័យក្មេង។ គ្រួសារមានឥទ្ធិពលគ្រប់ផ្នែកលើជីវភាពរបស់បុគ្គល និងទំនាក់ទំនងផ្ទាល់របស់ បុគ្គល។ គ្រួសារមានកំលាំងជំរុញខ្លាំងក្លាផ្នែកខាងមនោសញ្ចេតនាទៅលើបុគ្គលតាមរយៈបរិយាកាស និងការ អប់រំ មានទិសដៅជាកំណត់។ គ្រួសារបានផ្តល់នូវការរីកចម្រើនផ្នែកបញ្ញាស្មារតី សីលធម៌ ឆន្ទៈ មនោសញ្ចេតនា

[34] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

បណ្ដាគំរូសំរាប់ជីវភាពរស់នៅ និងទម្លាប់ក្នុងការធ្វើសកម្មភាពបណ្ដាលកត្តានៅក្នុងមជ្ឈដ្ឋានគ្រួសារដែលមានឥទ្ធិពលទៅលើការកកើត និងប្រែធាតុរបស់បុគ្គលឯកជនគឺ (កកើតកំហុសឆ្គងក្នុងចរិយាមាយាទ)៖

- អំពើល្មើស ឬអំពើប្រព្រឹត្តបទល្មើសរបស់សមាជិកមួយ ឬច្រើននៅក្នុងគ្រួសារ (ដូចជា លួច ការសម្លាប់ ជាដើម)
- អំពើដែលផ្ទុយសីលធម៌សង្គមដែលជាទម្លាប់របស់សមាជិកមួយឬច្រើននៅក្នុងគ្រួសារ (ដូចជា ស្រវឹង ញៀនគ្រឿងញៀន ជាដើម )
- បរិយាកាសតឹងតែងមានទំនាស់ប្រចាំនៅក្នុងគ្រួសារដូចជា ការឈ្លោះប្រកែករវាង សមាជិកគ្រួសារ ឪពុកម្ដាយ
- ការមិនគោរពចំពោះសីលធម៌ក្នុងការរស់នៅជាសហគមន៍ដូចជា គ្មានការជួយគ្នា សំរាលកិច្ចការរបស់គ្រួសារ
- គ្រួសារដែលមានកំរិតយល់ដឹងទាប មិនសូវបានរៀនសូត្រច្រើន។

បណ្ដាកត្តាអសកម្មនៅក្នុងជីវភាពរស់នៅសំរាកលំហែរកាយ និងទំនាក់ទំនងជាមួយមជ្ឈដ្ឋានជុំវិញមានឥទ្ធិពលទៅដល់ការកកើតនូវកំហុសឆ្គងក្នុងកិរិយាមាយាទរបស់បុគ្គល។បណ្ដាកត្តានោះអាចជាអំពើល្មើសច្បាប់ឬសណ្ដាប់ធ្នាប់សង្គម ការញៀនគ្រឿងស្រវឹង អំពើអសីលធម៌ផ្សេងនៅក្នុងផ្លូវកាមគុណរបស់បុគ្គលជនល្មើសហើយក៏អាចជាអំពើរបស់បុគ្គលដទៃទៀតដូចជារំលោភច្បាប់អំពើខ្វះសីលធម៌របស់មន្ត្រីរាជការនៅក្នុងស្ថាប័នរដ្ឋសាលារៀន ឬក្នុងសហគមន៍ណាមួយដែលបានប្រព្រឹត្តឡើងមក។[35]

### ២.១.១. តំបន់អនាធិតេយ្យ

ស្ថានភាពនៃគ្រួសារ តាមការសិក្សាស្រាវជ្រាវបានបង្ហាញអោយឃើញថាជនដែលមានគ្រួសារប្រព្រឹត្តបទល្មើសតិចជាងជនដែលមិនទាន់មានគ្រួសារ (ប្ដី ប្រពន្ធ)។ ឥទ្ធិពលរបស់គ្រួសារនីមួយៗខុសគ្នា អាស្រ័យទៅលើភាពសកម្ម ឬអសកម្មក្នុងការគ្រប់គ្រងត្រួតពិនិត្យនូវសកម្មភាពរបស់សមាជិកគ្រួសារ និងវិធីសាស្ត្រដោះស្រាយជីវភាពរស់នៅរបស់គ្រួសារនិងសមាជិកទាំងនោះ។

ការកកើតនូវគំនិតផ្ដួចផ្ដើមឈានដល់ការសម្រេចចិត្តប្រព្រឹត្តបទល្មើស និងការប្រព្រឹត្តបទល្មើសរបស់បុគ្គលណាមួយច្រើនតែផ្ដើមចេញពីគ្រួសារដែលមានជីវភាពខ្សត់ខ្សោយ គ្រួសារដែលមិនមានរចនាសម្ព័ន្ធគ្រប់គ្រាន់ដូចជា ឪពុក ឬម្ដាយស្លាប់ ឬលែងលះ គ្រួសារដែលរស់នៅគ្មានសុភមង្គល ដោយការខ្វះការទទួលខុសត្រូវរបស់សមាជិកគ្រួសារមិនមានសីលធម៌រស់នៅល្អប្រព្រឹត្តអំពើផ្ទុយច្បាប់។ល។ លក្ខខណ្ឌសំភារៈរចនាសម្ព័ន្ធគ្រួសារវិធីសាស្ត្រអប់រំនៅក្នុងគ្រួសារមានឥទ្ធិពលចំពោះភាពកកើត និងរីកចម្រើននៃអត្តចរិករបស់កុមារតូចៗ។

---

[35] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

វិជ្ជាជីវៈ និងសមាសភាពសង្គមៈ តាមរយៈការសិក្សាស្រាវជ្រាវឃើញថា បទល្មើសដែលត្រូវបានប្រព្រឹត្ត ដោយជនដែលពុំមានការងារធ្វើមានអត្រាខ្ពស់ ជាងជនដែលមានការងារជាពិសេសចំពោះបទល្មើសក្នុងករណី មិនរាងចាល។ ចំពោះមនុស្សដែលមានការងារធ្វើនោះជនល្មើសមានអត្រាខ្ពស់នៅក្នុងវិជ្ជាជីវៈដែលប្រើប្រាស់ ពលកម្មដៃជើងធ្ងន់ធ្ងរ និងក្នុងពលកម្មធម្មតាដូចជាកសិករ កម្មករសាងសង ដឹកជញ្ជូន កសិឧស្សាហកម្មដោយ ឡែកចំពោះបញ្ញាជន និងអ្នកចូលនិវត្តន៍នោះអត្រានៃជនល្មើសមានតិចជាង។ ម្យ៉ាងទៀតបទល្មើសមួយចំនួន អាចកើតឡើងអាស្រ័យដោយវិជ្ជាជីវៈ សមាសភាពសង្គមរបស់បុគ្គលនោះហេតុនេះការសិក្សាស្រាវជ្រាវអំពីបញ្ហា វិជ្ជាជីវៈសមាសភាពសង្គមរបស់បុគ្គលអាចអោយយើងរៀបចំបាននូវផែនការ និងទិសដៅសកម្មភាពរួមទាំងវិធី សាស្ត្រសំរាប់ការបង្កា ទប់ស្កាត់ បទល្មើសទៅលើវិស័យ និងវិជ្ជាជីវៈរួមទាំងសមាសភាពសង្គមរបស់មនុស្ស។

ក្រៅពីបញ្ហាខាងលើសញ្ញាផ្សេងទៀតនៃបុគ្គលក្នុងសង្គមរួមមានតួនាទីសង្គម ទីកន្លែងស្នាក់ នៅតំបន់ រស់នៅ (ទីក្រុង ជនបទ) មានសារសំខាន់នៅក្នុងការស្រាវជ្រាវអំពីបុគ្គលិកលក្ខណៈរបស់បទល្មើសណាស់។

លក្ខណៈសំគាល់នៃបុគ្គលក្នុងសង្គម គឺជាសញ្ញាខាងក្រៅដោយឡែកលក្ខណៈសំគាល់ផ្នែកសីលធម៌ ចិត្តសាស្ត្រ គឺជាផ្នែកខាងក្នុងនៃបុគ្គលិកលក្ខណៈរបស់ជនល្មើស។ ផ្នែកខាងក្នុងនៃបុគ្គលិកលក្ខណៈជនល្មើស ត្រូវបានស្តែងឡើងតាមរយៈបណ្តាសញ្ញាផ្សេងៗ ចំណុះអោយស្មារតី មនសិការហើយដែលលក្ខណៈសំគាល់នេះ ធ្វើអោយយើងបានថាតើហេតុអ្វីបានជាជននោះ ប្រព្រឹត្តបទល្មើស។[36]

លក្ខណៈសំគាល់នេះ ត្រូវបានលេចតាមរយៈទស្សនៈ ការយល់ដឹង អាកប្បកិរិយារបស់បុគ្គល ចំពោះតំលៃ នៃសីលធម៌ និងកំរិតនៃយល់ដឹងចំពោះតំលៃសង្គមរបស់បុគ្គលនោះដូចជាចំពោះកាតព្វកិច្ចរបស់ពលរដ្ឋចំពោះ មាតុភូមិ ពលកម្ម ច្បាប់ ចំពោះគ្រួសារ ចំពោះបុគ្គលផ្សេងទៀតជុំវិញខ្លួន និងចំពោះខ្លួនឯងផ្ទាល់។ នៅពេលដែល បុគ្គលដែលបុគ្គលនោះកំណត់អំពីទិសដៅណាមួយចំពោះតំលៃ សង្គមណាមួយ (យល់ថាច្បាប់ត្រូវគោរព ឬ មើលស្រាលច្បាប់) នោះយើងអាចវាយតំលៃបាននូវទិសដៅនៃការរីកចម្រើននៃចរិករបស់ជននោះទំហំនៃការវិវត្ត ន៍នៃចរិករបស់បុគ្គលតាមទិសដៅត្រឹមត្រូវមាន ប្រយោជន៍សំរាប់សង្គម ឬបង្កមានការអន្តរាយដល់សង្គម។

### ២.១.២. តំបន់ដាច់ស្រយាល

អត្តចរិតរបស់បុគ្គល បទល្មើសក៏ដូចជាសកម្មភាពទាំងអស់របស់មនុស្សប្រសិនបើពិនិត្យអោយបានស៊ី ជម្រៅនិងទីបំផុតនោះគឺជាលទ្ធផលដែលកើតចេញអំពីឥទ្ធិពលទៅវិញទៅមករវាងស្ថាប័ន ឯកជន និងមជ្ឈដ្ឋាន សង្គមខាងក្រៅ។ ឥទ្ធិពលនៃកត្តាទាំងពីរបានធ្វើអោយមានការសម្រេចចិត្តរបស់បុគ្គលណាមួយក្នុងការប្រព្រឹត្ត

[36] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

បទល្មើសត្រូវបានស្តែងឡើងពិតប្រាកដ។ ដូចនេះមូលហេតុ និងលក្ខខណ្ឌនៃបទល្មើសមួយស្តែងឡើងនៅក្នុងលក្ខណៈពិសេសនៃតម្រូវការផលប្រយោជន៍ទស្សនៈទំនាក់ទំនង និងគំនិតផ្តួចផ្តើម (មូលហេតុអត្តនោម័ត) របស់បុគ្គលនោះ និងមួយផ្នែកទៀតស្តែងឡើងនៅក្នុងមជ្ឈដ្ឋានសង្គមខាងក្រៅដែលកំណត់ និងបង្កអោយមានគំនិតផ្តួចផ្តើមនិងការសម្រេចចិត្តប្រព្រឹត្តបទល្មើស។[37]

ការវិភាគលើមូលហេតុ និងលក្ខខណ្ឌនៃបទល្មើសត្រូវបានពិនិត្យទៅលើអត្ថន័យនៃបញ្ហាដូចខាងក្រោម៖

- រចនាសម្ព័ន្ធចិត្តសាស្ត្រ សង្គមនៃបទល្មើស
- បណ្តាករណីដែលមានឥទ្ធិពលដល់ការកកើតឡើងកំហុសឆ្គងក្នុងចរិយាមាយាទរបស់បុគ្គល និងតួនាទីរបស់វានៅក្នុងរចនាសម្ព័ន្ធនៃបទល្មើស
- ការវិវត្តន៍ជាក់ស្តែង និងតួនាទីរបស់វានៅក្នុងរចនាសម្ព័ននៃបទល្មើស
- កត្តាជនរងគ្រោះនៅក្នុងមូលហេតុ និងលក្ខខណ្ឌនៃបទល្មើស

រចនាសម្ព័ន្ធចិត្តសាស្ត្រសង្គមនៃបទល្មើសនៅទីនេះមានអត្ថន័យទូលំទូលាយ។ បទល្មើសមានន័យរួមទាំងកំណកំណើតនៃបំណងប្រព្រឹត្តបទល្មើស (អត្តនោម័ត) និងការប្រព្រឹត្ត (ស្តែងចេញ)នូវគោលបំណងនោះផងដែរ។ បទល្មើស គឺជារយៈកាលមួយនៃការវិវឌ្ឍន៍បាតុភូតផ្លូវចិត្តដែលមានតួនាទីកំណត់នូវសកម្មភាពជាសត្យានុម័តរបស់មនុស្សដែលរួមផ្សំជាបទល្មើស។

មជ្ឈដ្ឋានសង្គម ឫការវិវឌ្ឍន៍នៃបាតុភូតផ្លូវចិត្តរបស់បុគ្គលតែឯកឯងមិនអាចក្លាយជាមូលហេតុ ឫលក្ខខណ្ឌនៃការប្រព្រឹត្តបទល្មើសជាក់ស្តែងឡើយប៉ុន្តែការគួបផ្សំ ឥទ្ធិពលនៃកត្តាទាំងពីរនេះនឹងក្លាយជាមូលហេតុ និងលក្ខខណ្ឌនៃបទល្មើស។

រចនាសម្ព័ន្ធនៃបទល្មើស គឺជាបាតុភូតដែលតែងតែកើតមានការផ្លាស់ប្តូរអាស្រ័យទៅដោយការវិវត្តន៍មជ្ឈដ្ឋានខាងក្រៅ និងឥទ្ធិពលរវាងមជ្ឈដ្ឋាននោះជាមួយនឹងសភាវៈផ្លូវចិត្តរបស់បុគ្គល។ រចនាសម្ព័ន្ធនៃបទល្មើសរួមមាន៖

- ដំណាក់កាលកកើត នូវគំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស (មូលហេតុ)
- ការធ្វើផែនការសកម្មភាពប្រព្រឹត្តបទល្មើស (ការសម្រេចចិត្ត)
- ការប្រព្រឹត្តបទល្មើស (ការស្តែងចេញនៃគំនិតផ្តួចផ្តើម និងផែនការ)

---

[37] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

នៅក្នុងដំណាក់កាលកកើត គំនិតផ្តើមរួមមានតម្រូវការរបស់បុគ្គលការត្រិះរិះពិចារណាបំណងប្រាថ្នាផលប្រយោជន៍ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ភាពរំជួលអារម្មណ៍ក្រៅស្ថានភាពជាក់ស្តែង ចំណងចំណូលចិត្តសេចក្តីត្រូវការនូវផលប្រយោជន៍រួមទាំងការកំណត់វាយតម្លៃរបស់បុគ្គលមានឥទ្ធិពលទៅវិញទៅមក បង្កអោយមានគំនិតផ្តួចផ្តើម និងបញ្ចូលវាទៅក្នុងតែសកម្មភាពប្រព្រឹត្តបទល្មើស(ការសម្រេចចិត្ត)។[38] នៅក្នុងដំណាក់កាលនេះបុគ្គលដែលជាប្រធាននៃសកម្មភាពនេះ អាចកំណត់អំពីទិសដៅសកម្មភាព ពេលវេលា ទីកន្លែង រៀបចំនូវផែនការសំរាប់ធ្វើសកម្មភាពសមស្របសំរាប់ការប្រព្រឹត្តបទល្មើស។ ការធ្វើសកម្មភាពប្រព្រឹត្តដោយផ្ទាល់នូវបទល្មើសរួមមានសកម្មភាព អកម្ម និង ការអន្តរាយដល់សង្គមដែលបង្កដោយអំពើទាំងនោះ។

បទល្មើសត្រូវបានកកើតឡើងដោយសារឥទ្ធិពលនៃកត្តាខាងក្រៅ (មជ្ឈដ្ឋានសង្គម) និងកត្តាខាងក្នុងរបស់បុគ្គលឯកជន។ រចនាសម្ព័ន្ធនៃបទល្មើសធាតុពិតគឺ ជាការផ្សព្វផ្សាយ ភ្ជាប់បុគ្គលទៅនឹងមជ្ឈដ្ឋានសង្គម ដូចនេះដើម្បីវិភាគអោយបានជ្រៅជ្រះត្រូវពិនិត្យវានៅក្នុងទំនាក់ទំនង និងភាពផ្សាភ្ជាប់នៃបាតុភូតនោះ។

បណ្តាលករណីដែលមានឥទ្ធិពលដល់ការកកើតនូវកំហុសឆ្គង នៅក្នុងចរិយាមាយាទរបស់បុគ្គលៈកត្តាអសកម្មនៅក្នុងមជ្ឈដ្ឋានរស់នៅ មានឥទ្ធិពលដល់ការផ្លាស់ប្តូរនូវទស្សនៈរបស់ បុគ្គលហើយជាទូទៅវាស្តែងនៅក្នុងរចនាសម្ព័ន្ធនៃបទល្មើស។ ម្យ៉ាងវិញទៀតទំនាក់ទំនងមិនស្របគ្នារវាងបុគ្គល និងសង្គម រវាងការទាមទាររបស់សង្គមម និងតម្រូវការរបស់បុគ្គលក៏ត្រូវបានស្តែងឡើងនៅក្នុងរចនាសម្ព័ន្ធនៃបទល្មើសផងដែរ។ ទំនាស់រវាងផលប្រយោជន៍ការទាមទាររបស់សង្គម និងផលប្រយោជន៍របស់បុគ្គលបានបង្កអោយមានការកកើតនិងពង្រឹងនូវមូលនៃបទល្មើស ហើយដែលជាមូលហេតុដោយ ឡែកនៃការប្រព្រឹត្តបទល្មើស។

### ២.២. ស្ថានភាពរីកចម្រើនបច្ចេកវិទ្យា

នាពេលបច្ចុប្បន្ន ការវិវត្តន៍សង្គម មានភាពរីកចម្រើនខ្លាំងបំផុត លើគ្រប់វិស័យជាច្រើននៅក្នុង នោះក៏មានការរីកចម្រើនឡើង ផ្នែកបច្ចេកវិទ្យា បានលេចជារូបរាង និងមានការពេញនិយមជាខ្លាំង ព្រមជាមួយនឹង កំរិតនៃបទល្មើសក៏បានប្រែប្រួលទៅតាមការវិវត្តនេះផងដែរ។ ចំពោះបទល្មើស ដែលពាក់ព័ន្ធបច្ចេកវិទ្យានេះមានទម្រង់នឹងរូបភាពជាច្រើនបានកើតមានឡើងដូចជា៖

#### ២.២.១. ទំនើបកម្មនៃសំភារៈនិយម

ចំពោះការជឿនលឿន បច្ចេកវិទ្យាគឺបានធ្វើអោយការរស់នៅមានភាពល្អប្រសើររបស់ប្រជាជនទូទៅរួមជាមួយនឹងមធ្យោបាយសំភារៈប្រើប្រាស់របៀបនៃការទំនាក់ទំនងគ្នាគ្រប់ប្រភេទ។ ចំណែកបទល្មើសនៅក្នុងវិស័យបច្ចេកវិទ្យាក៏មានភាពជឿនលឿនតាមនឹងផងដែរដោយបានដេញតាមការវិវត្តន៍នៃទំនើបកម្មនេះ។

[38] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

សំភារៈនិយមទាំងនោះមានដូចជា ការប្រើប្រាស់ ឡាន ទូរស័ព្ទ ជាដើម។ នេះជាហេតុដែលធ្វើអោយជនល្មើសសម្លឹងឃើញនូវរបស់ទាំងនោះ នឹងបានបង្កើតជាចិត្តចង់បានក្នុងការបំពេញតំរូវការខ្លួនហេតុដែលនាំអោយមានបទល្មើស។[39] កត្តានៃការប្រើប្រាស់សំភារៈ ចំពោះទូរស័ព្ទវិញវាបានផ្តល់ភាពងាយស្រួលដល់ការរស់នៅរៀនសូត្រ និងជីវភាពប្រចាំពិតប្រាកដដែលយើងមិនអាចប្រកែកបានឡើយចំពោះគុណប្រយោជន៍នៃសំភារៈនិយមដូចជាទូរស័ព្ទ ប៉ុន្តែក៏មានគុណវិបត្តិផងដែលនៅក្នុងអំឡុងពេលបុគ្គលណាមួយគាត់បានប្រើប្រាស់ដោយខុសច្បាប់នូវច្បាប់បច្ចេកវិទ្យា។ វាបានផ្តល់ផលប៉ះពាល់ខ្លាំងបំផុតដល់អនាគតសកម្មភាពទាំងនោះមានដូចជាការប្រើអ៊ីធើណែតដោយចូលក្នុងក្នុង វេបសាយ អាសអាភាស ជាដើម វាបានធ្វើអោយប៉ះពាល់ ទៅដល់អារម្មណ៍របស់ជននោះ នឹងអាចធ្វើអោយគាត់មានបំណងចង់ប្រព្រឹត្តបទល្មើសតាមវីដេអូនោះផងដែរ។ ការប្រើប្រាស់អាសយដ្ឋានដើម្បីប្រតិបត្តិការលើសកម្មភាពណាមួយជនរងគ្រោះបានបង្ហាញថាខ្លួននៅទីណាកត្តានេះក៏អាចជាកកើតជាបទល្មើសផងដែរ ប្រសិនបើជនរងគ្រោះនោះមានផលប្រយោជន៍ដល់សកម្មភាពនៃបទល្មើសមួយទៀតការប្រើប្រាស់បច្ចេកវិទ្យា ថតរូបបង្ហោះជាដើម។ ក៏ជាមូលហេតុដោយប្រយោលក្នុងអំពើល្មើសណាមួយនៅក្នុងសង្គមដោយមិនបានដឹងខ្លួនមុនជាពិសេសដូចជា ឡានទំនើប ដោយសារតែគិតថាឡានទំនើបជនល្មើសបានបើកបរដោយមិនប្រុសប្រយ័ត្នក៏ជាកត្តាមួយផងដែរ។

### ២.២.២. បច្ចេកវិទ្យាទំនើប

បច្ចេកវិទ្យាទំនើប មានភាពរីកចម្រើនធ្វើអោយមានភាពងាយស្រួលក្នុងការទំនាក់ទំនងជនល្មើសបានយកមធ្យោបាយនេះប្រើប្រាស់ ដោយសារតែវាជាទំនើបកម្មមួយដែលទាក់ទងនឹងភាពជឿនលឿន។ តាមការសង្កេតអាចមើលឃើញនូវទិដ្ឋភាពបទល្មើសមួយចំនួន នៃការលួចប្រាក់ពីគណនីធនាគាររបស់អ្នកណាមួយដែលជាជនរងគ្រោះដោយសារតែការមិនសូវយល់ច្បាស់ពីការប្រើប្រាស់ ប្រព័ន្ធបច្ចេកវិទ្យា របស់ជនរងគ្រោះឃើញបែបនេះសកម្មភាពនេះក៏បានកើតឡើងសួរថាតើជនល្មើសប្រើប្រាស់នូវអ្វី? គឺបច្ចេកវិទ្យាទំនើបដូចជាការហែកចូលទៅក្នុងគណនី ឬប្រើប្រាស់មធ្យោបាយផ្សេងៗទៅតាមបទល្មើសទាំងនោះ។

ចំពោះបទល្មើស គឺផ្តោតសំខាន់លើបច្ចេកវិទ្យាទំនើបលើជនរងគ្រោះដោយប្រើប្រាស់ដូចគ្នាទៅនឹងប្រភេទនៃបទល្មើសបុគ្គលទាំងនោះអាចនិយាយបានថា គឺមេរោគនៅប្រព័ន្ធបច្ចេកវិទ្យាទំនើប។

[39] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

## ៣. វិធានការដោះស្រាយ និងវិធានការទប់ស្កាត់

វិធានការដែលដោះស្រាយពាក់ព័ន្ធ មូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គមកម្ពុជា គឺត្រូវមានការចូលរួមពីគ្រប់ស្ថាប័នគ្រប់វិស័យទើបអាចទប់ស្កាត់បានចំពោះការកកើតបទល្មើសនេះ មិនមែនគ្រាន់តែមានការបង្កើតច្បាប់មានតែអ្នកអនុវត្តច្បាប់គ្រប់គ្រាន់ ត្រូវមានការចូលរួមជាពិសេសគឺប្រជាពលរដ្ឋនៃប្រទេសរួមគ្នាក្នុងការដោះស្រាយដោយមានវិធានការដូចជា៖

### ៣.១. យន្តការរបស់សង្គម

សង្គមគឺជាផ្នែកមួយនៃការវិវឌ្ឍន៍ និងភាពរីកចម្រើនទន្ទឹមនឹងនេះផងដែលបទល្មើសក៏បានលេចឡើងសញ្ញាណផងដែរនៅក្នុងទិដ្ឋភាពសង្គម។[40] ដូចនេះសង្គមគប្បីត្រូវតែមានវិធានការទប់ស្កាត់ និងបង្កាបទល្មើសដូចខាងក្រោម៖

#### ៣.១.១. វិធានការស្មារតី

ចំពោះវិធានការស្មារតី នៅក្នុងអត្តន័យនេះគឺចង់ផ្តោតសំខាន់លើស្មារតីនៃការទទួលខុសត្រូវចំពោះសកម្មភាពនៃបទល្មើសដែលបានកើតឡើងមិនមែនមានតែអ្នកដឹកនាំនោះទេ គឺត្រូវចេញពីការចូលរួមទាំងអស់គ្នាទាំងអ្នកអនុវត្តច្បាប់ប្រជាពលរដ្ឋជាដើម ដែលមានដូចជា ការយកចិត្តទុកដាក់ចំពោះ ការបង្ក្រាបបទល្មើសដោយពង្រឹងវិស័យច្បាប់ កំណត់បង្ហាញអំពីការដឹកនាំ កិច្ចការដែលពាក់ព័ន្ធនឹងបទល្មើសដែលបានកើតឡើង។

- ជំរុញឲ្យមានការគោរពច្បាប់តាមរយៈការផ្សព្វផ្សាយ
- លើកទឹកចិត្តដល់អ្នកអនុវត្តច្បាប់
- លើកកម្ពស់ការការអនុវត្តច្បាប់

#### ៣.១.២. វិធានការសំភារៈ

វិធានការសំភារៈមានន័យថាគឺជាភាពមួយដែលត្រូវបំពេញឡើង ដោយខានមិនបានវិធាន នេះគឺបានលើកកម្ពស់ ដោយបង្កាកុំអោយមានបទល្មើសកើតឡើងជាបន្តបន្ទាប់ទៀត។

- មានសំភារៈការប្រើប្រាស់ គ្រប់គ្រាន់ដែលទាក់ទងការរីកចម្រើន
- បង្កើនការវិធានការសំភារៈតាមរយៈកិច្ចការដែលបានលើកឡើង
- ការបង្កើតអោយមានទីតាំងសំភារៈ ដោយមានភាពល្អប្រសើ និងមានគុណភាព
- ការគ្រប់អោយអោយមានប្រសិទ្ធិភាព

[40] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

## ៣.២. យន្តការឧក្រិដ្ឋវិទ្យា ច្បាប់ និងការអនុវត្តច្បាប់

ចំពោះយន្តការឧក្រិដ្ឋវិទ្យា ច្បាប់ និងការអនុវត្ត ពិតជាមិនអាចខ្វះបានមួយណាឡើយ ក្នុងការ ស្វែងរក មូលហេតុបទល្មើស ដែលកើតឡើងនៅក្នុងសង្គម រួមជាមួយទំនាក់ទំនង កត្តាដែលបង្កអោយ មានអំពើល្មើសកើតមាន។

### ៣.២.១. វិធានការឧក្រិដ្ឋវិទ្យា

ឧក្រិដ្ឋវិទ្យាមាន លក្ខណៈអរូបីយ៍ក៏ប៉ុន្តែឧក្រិដ្ឋវិទ្យាមានសារៈសំខាន់ណាស់សំរាប់ការីកចម្រើនរបស់សង្គម។ ដោយបច្ចុប្បន្នឧក្រិដ្ឋវិទ្យាមានភារកិច្ចចំបងបីៈ

ទី១.ការពារការរំលោភច្បាប់

ទី២.វិភាគរកមូលហេតុបទល្មើស

ទី៣.ផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវសំរាប់អ្នកអនុវត្តដោយធ្វើជាសំណើ ឬអនុសាសន៍ក្នុងកំរិតបច្ចេកទេស។ ដើម្បីឲ្យភារកិច្ចទាំងនេះបានសំរេច និងទទួលបាននូវលទ្ធផលល្អនៅក្នុងវិធីសាស្ត្ររបស់ឧក្រិដ្ឋវិទ្យាដាច់ខាតត្រូវមានអ្នកឯកទេសផ្សេងទៀតចូលរួមធ្វើការស្រាវជ្រាវ។ អ្នកទាំងនោះមានដូចជាអ្នកច្បាប់ អ្នកសង្គមសាស្ត្រ អ្នកសេដ្ឋកិច្ច អ្នកចិត្តសាស្ត្រការចូលរួមរបស់អ្នកជំនាញផ្សេងៗគ្នាទាំងនេះគឺត្រូវបានស្រាវជ្រាវតាមកម្មវត្ថុដែលទាក់ទងនឹងការល្មើសក្នុងសង្គម។

ការចូលរួមរបស់អ្នកជំនាញផ្សេងៗគ្នា ទាំងនេះគឺត្រូវស្រាវជ្រាវតាមកម្មវត្ថុដែលទាក់ទងនឹងការល្មើសក្នុងសង្គម។ ឧទាហរណ៍ៈ សិក្សាស្រាវជ្រាវពីបទល្មើសទាក់ទងទ្រព្យសម្បត្តិត្រូវមានអ្នកជំនាញខាងសេដ្ឋកិច្ច និងអ្នកជំនាញ ខាងចិត្តសាស្ត្រ។ ចំណេះដឹងផ្នែកសេដ្ឋកិច្ចក្នុងករណីនេះចូលរួមវិភាគស្ថានភាពសេដ្ឋកិច្ចសង្គម និងស្ថានភាពគ្រួសាររបស់ជនល្មើសទៅតាមជីភាពជាក់ស្តែង។ រីឯចំណេះដឹងផ្នែកចិត្តសាស្ត្រត្រូវការ វិភាគអត្តសញ្ញាណឧក្រិដ្ឋជន ផ្នែកស្មារតី អារម្មណ៍ជាដើម។

យើងដឹងហើយថា ឧក្រិដ្ឋវិទ្យាជាវិទ្យាសាស្ត្រសង្គមដូច្នេះលក្ខណៈវិធីសាស្ត្រនៃការស្រាវជ្រាវត្រូវផ្អែកលើទ្រឹស្តីសង្គម និងទ្រឹស្តីនីតិ។ ល្គឹកណាគ្មានការវិភាគដោយផ្អែកលើមូលដ្ឋាននោះទេនោះការធ្វើការប្រឆាំងនឹងឧក្រិដ្ឋភាព មិនអាចមានប្រសិទ្ធិភាពបានឡើយជាទូទៅការអនុវត្តនីតិវិធីសាស្ត្ររបស់ឧក្រិដ្ឋវិទ្យាទាក់ទងនឹងបទដ្ឋានច្បាប់ហើយមិនត្រឹមតែច្បាប់ព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ និងប្រតិបត្តិព្រហ្មទណ្ឌប៉ុណ្ណោះទេគឺថែមទាំងច្បាប់រដ្ឋប្បវេណី ច្បាប់រដ្ឋបាលថែមទៀត។ ក្នុងការស្រាវជ្រាវរបស់ឧក្រិដ្ឋវិទ្យាជាញឹកញាប់ប្រើប្រាស់វិធីរបស់អ្នកសង្គមវិទូដូចជាអនុវត្តស្ថិតិវិធី ទំរង់វិធី ការសំភាស៍ ការវាយតម្លៃនៃកោសល្យវិច្ច័យ។ល។ វិធីទាំងអស់នេះឧក្រិដ្ឋវិទ្យាអនុវត្តក្នុងការស្រាវជ្រាវលើឧក្រិដ្ឋភាព និងបានជោគជ័យជាទីបំផុត។

ជំហានដំបូងនៃការស្រាវជ្រាវ ទាមទារនូវការរៀបចំបានគ្រប់ជ្រុងជ្រោយ ដូចជាប្រមូលឯកសារជាដើម ការវាយតម្លៃលទ្ធផលរបស់អ្នកជំនាញផ្សេងៗដែលប្រមូលបានធ្វើសេចក្តីសន្និដ្ឋានផ្អែកតាមឯកសារ ដើមដែលទទួលបាន និងធ្វើការស្រាវជ្រាវដាច់ខាតត្រូវបង្ហាញថាវាជាបញ្ហាសំខាន់បំផុត។ ឧទាហរណ៍៖ ឧក្រិដ្ឋភាពស្ត្រីជាប្រធានបទមួយដែលនឹងត្រូវធ្វើការស្រាវជ្រាវ។[41] ដូច្នេះជាបឋមត្រូវពិនិត្យមើលថាតើបញ្ហានេះពីមុនមកគេបានធ្វើការស្រាវជ្រាវឬទេ? បើបានធ្វើស្រាវជ្រាវតើនោះបែបណា? រីឯសំណើឬអនុសាសន៍មានដែរឬគ្មាន? និងជាពិសេសត្រូវពិនិត្យមើលការអនុវត្តន៍ក្រោយពីបានធ្វើការស្រាវជ្រាវមានប្រសិទ្ធិភាពដូចម្តេចខ្លះ?

ក្រោយពីធ្វើការរៀបចំស្រាវជ្រាវរួចហើយត្រូវកំណត់ទិសដៅ និងភារកិច្ចដើម្បីស្រាវជ្រាវ។ ក៏ប៉ុន្តែការកំណត់ទិសដៅ និងភារកិច្ចអាស្រ័យនឹងកត្តារៀបចំសំរាប់ធ្វើការស្រាវជ្រាវដូចជា អ្នកដឹកនាំស្រាវជ្រាវ ការប្រើប្រាស់កំលាំង និងមធ្យោបាយការប្រើប្រាស់ប្រភពពត៌មាន និងលក្ខខណ្ឌផ្សេងៗទៀតដែលទាក់ទងនឹងការស្រាវជ្រាវឧក្រិដ្ឋភាព។ ជាទូទៅឧក្រិដ្ឋវិទ្យាស្រាវជ្រាវធ្វើឡើងដោយក្រុមឧក្រិដ្ឋវិទូ និងអ្នកអនុវត្តដោយយោងទៅតាមគំរោងស្រាវជ្រាវបែបវិទ្យាសាស្ត្រ។

ទំហំ និងបរិមាណរបស់ឧក្រិដ្ឋវិទ្យាស្រាវជ្រាវ ត្រូវកំណត់ទៅតាមទិសដៅ និងភារកិច្ចដែលត្រូវស្រាវជ្រាវ និងជាពិសេស វាអាស្រ័យនឹងកម្មវត្ថុស្រាវជ្រាវដំណាក់កាលស្រាវជ្រាវដែនដីនិយាយរួមឲ្យតែអ្វីដែលស្ថិតនៅក្រោមការស្រាវជ្រាវ។ ប៉ុន្តែក្នុងករណីនេះចាំបាច់ត្រូវតែវិភាគស្ថានភាពសេដ្ឋកិច្ចនៅក្នុងដំណាក់កាលដែលស្រាវជ្រាវ។

នៅក្នុងកម្មវិធីស្រាវជ្រាវត្រូវយកចំណេះដឹងទ្រឹស្តីផ្សារភ្ជាប់នឹងភាពជាក់ស្តែងដើម្បីធ្វើការស្រាវជ្រាវ។ គ្រប់អក្សរសិល្បដែលពាក់ព័ន្ធត្រូវយកមកអនុវត្ត។ ចំពោះប្រភពពត៌មានស្តីពីឧក្រិដ្ឋភាពគឺស្ថិតិព្រហ្មទណ្ឌ ដែលផ្តល់ពត៌មានស្តីពីសកម្មភាពស្ថាប័នការពារសន្តិសុខ ប្រឆាំងនឹងបទល្មើសក្នុងនោះមានការព្រមានបទល្មើសផ្ទាល់តែម្តង។ ស្ថិតិព្រហ្មទណ្ឌមានសារៈប្រយោជន៍ក្នុងការស្រាវជ្រាវព្រោះថាបង្ហាញបរិមាណបទល្មើស និងបុគ្គលប្រព្រឹត្តបទល្មើស។ ដូច្នេះតាមប្រភពនេះយើងអាចវាយតម្លៃបី យ៉ាងគឺ ទី១. វាយតម្លៃទៅលើបទល្មើស និងទី២. វាយតម្លៃតៅលើបុគ្គលប្រព្រឹត្តបទល្មើស និងទី៣. ទណ្ឌកម្មដែលបានផ្តន្ទាទោស។

ការទប់ស្កាត់ និងការបង្ការបទល្មើស (ព្យាករណ៍អំពីបទល្មើស)

សរុបសេចក្តីមក វិធីសាស្ត្រឧក្រិដ្ឋវិទ្យាស្រាវជ្រាវជាវិធីដែលមានលក្ខណៈពិបាក។ ផ្អែកលើមូលដ្ឋានទ្រឹស្តីវិធីនេះវិភាគតាមមូលសាស្ត្រ:

វិភាគបទល្មើស ក្នុងមជ្ឈដ្ឋានសង្គមដោយប្រើវិធីសាស្ត្រដូចជា សង្គមសាស្ត្រ ចិត្តសាស្ត្រ។

---

[41] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

ការវិភាគឧក្រិដ្ឋភាព គឺវិភាគបាតុភូតដែលមានទំនាក់ទំនងជាមួយបទល្មើស។ កត្តានេះចាំបាច់ណាស់ត្រូវស្រាវជ្រាវមជ្ឈដ្ឋានក្នុង និងមជ្ឈដ្ឋានក្រៅឧក្រិដ្ឋភាព។ មជ្ឈដ្ឋានក្នុងបទល្មើស គឺសំដៅទៅលើអត្តសញ្ញាណនៃការល្មើស និងសិក្សាវិភាគដោយលំអិតជាទីបំផុត។ មជ្ឈដ្ឋានក្រៅបទល្មើសគឺជាសង្គម និងស្ថានភាពសង្គមដែលជំរុញឲ្យមានការប្រព្រឹត្តបទល្មើស។

### ៣.២.២ វិធានការផ្លូវច្បាប់ និងការអនុវត្តច្បាប់

**វិធានការផ្លូវច្បាប់៖**

ជាការដែលមានច្បាប់មួយពិតប្រាកដបានចងក្រង រៀបរៀងបានល្អដោយបានឆ្លងការយល់ព្រម ដាក់អោយប្រើប្រាស់ដោយមានការចូលរួមពិភាក្សាច្បាប់ដូចជា នីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ និងខាងក្រៅផ្សេងទៀតនៅក្នុងគោលបំណងអោយច្បាប់នោះមានភាពល្អប្រសើរឡើង។ ការបង្កើតច្បាប់ គឺវាជារឿងមួយដែលត្រូវតែមានអ្នកជំនាញពីគ្រប់ស្ថាប័នដើម្បីចូលរួមក្នុងការបង្កើតច្បាប់ណាមួយ ទោះបីជាច្បាប់នោះមានគោលបំណងឬអត្ថន័យយ៉ាងណាក៏ដោយគប្បីមានអ្នកជំនាញមួយដ៏ត្រឹមត្រូវ។

ការដាក់ទណ្ឌកម្ម នៅពេលដែលបង្កើតច្បាប់នីមួយៗគោលបំណង អត្ថន័យ ជារឿងសំខាន់តែមិនត្រូវមើលរំលងការដាក់ទណ្ឌកម្មលើបទល្មើសឡើយពីព្រោះថាប្រសិនបើបទល្មើសមួយ មានលក្ខណៈមិនសូវធ្ងន់ធ្ងរទេហើយការដាក់ទោសបែរជាធ្ងន់នោះវានឹងបង្កបញ្ហាដល់សង្គមជាក់ជាមិនខានឡើយ។

**ការអនុវត្តច្បាប់៖**

ជាការពិតណាស់ នៅពេលដែលមានច្បាប់ល្អប្រសើរហើយការអនុវត្តជារឿងមួយផ្សេងទៀតដែលមិនអាចខ្វះបានដោយសារតែច្បាប់បានបញ្ញត្តិក្នុងសៀវភៅ ឫទុកក្នុងអ្វីមួយដូច្នេះប្រសិនបើចង់ឲ្យច្បាប់នោះអនុវត្តបានល្អត្រូវតែយកច្បាប់នោះទៅអនុវត្តដោយអ្នកអនុវត្តច្បាប់អោយបានល្អ និងមានវិជ្ជាជីវៈអោយស្របតាមក្របខណ្ឌ និងកម្រិតនៃការអនុវត្តទៅលើអ្វីមួយ។ នៅក្នុងការអនុវត្តនេះ គឺត្រូវមានដូចខាងក្រោម៖

- ពង្រឹងលើការអនុវត្តលើអ្នកអនុត្តច្បាប់៖ មានន័យថាការអនុវត្តច្បាប់ ពាក់ព័ន្ធនឹងបុគ្គល ឬក្រុមណាមួយដូច្នេះសមត្ថភាពនៃការយល់ដឹងផ្នែកច្បាប់ជារឿងសំខាន់បំផុតដោយមិនអាចមើលរំលងបានឡើយ។
- ការអនុវត្តអោយស្របតាមច្បាប់៖ នៅពេលដែលមានអ្នកអនុវត្តច្បាប់រួចហើយអ្នកអនុវត្តត្រូវតែ ធ្វើឱ្យស្របទៅតាមផ្លូវច្បាប់ដែលបានចែងដោយមិនអាចបំពានខុសច្បាប់ រំលោភទៅលើផលប្រយោជន៍ណាមួយឡើយ។[42]

[42] សៀវភៅ ឧក្រិដ្ឋវិទ្យា (លោកបណ្ឌិត ស៊ិន រិទ្ធ)

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការសិក្សាស្រាវជ្រាវសារណា ស្តីពី**មូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គមកម្ពុជា** នេះ បញ្ជាក់ឲ្យឃើញអំពីស្ថានភាពនៃបទល្មើសដែលកំពុងតែបានកើតឡើងជារៀងរាល់ថ្ងៃនៅក្នុងសង្គមជាក់ស្តែងតើមូលហេតុអ្វីបានជាកើតមានបទល្មើស?បណ្តាលមកពីកត្តាអ្វីខ្លះ? តើគួរគប្បីមានវិធានការទប់ស្កាត់នូវបទល្មើសយ៉ាងដូចម្តេច? ឆ្លងកាត់តាមរយៈការសិក្សាប្រធានបទមួយនេះ បានកំណត់ ០៣ ចំណុចសំខាន់ដែលបានលើកយកមកស្រាវជ្រាវមានដូចជាទី១.**ទិដ្ឋភាពទូទៅនៃបទល្មើសនៅក្នុងសង្គមកម្ពុជា** ទី២.**ការដាក់ទោស និងការអនុវត្តទោស** និងទី៣.**មូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គមកម្ពុជា** ។

**ការសិក្សាអំពីទិដ្ឋភាពទូទៅនៃបទល្មើស** គឺជាការសិក្សាពីទិដ្ឋភាពរួមដែលបទល្មើសមួយបានកើតឡើងផ្អែកលើស្ថានភាពនៃសង្គមកម្ពុជាដោយហេតុថាបទល្មើសមួយចំនួនបានកើតមានជាញឹកញាប់ដូចជាបទល្មើសចរាចរណ៍ គ្រឿងញៀន និងបទល្មើសដែលមានលក្ខណៈបែបទំនើបស្របតាមការវិវត្តន៍នៃបច្ចេកវិទ្យាដូចជាបទល្មើសបច្ចេកវិទ្យា ការឆបោក ការគំរាមកំហែង តាមប្រព័ន្ធអ៊ីនធើណែត និងការលាងសម្អាតប្រាក់ជាដើមដែលកំពុងតែកើតមានឡើងនឹងកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។

ចំណែកឯការសិក្សាពី**ការដាក់ទោស និងការអនុវត្តទោស** ចំពោះបទល្មើសមួយដែលបានកើតឡើងនៅក្នុងសង្គមជាភាពមួយចាំបាច់ដោយស្របតាមការបញ្ញត្តិរបស់ច្បាប់ និងបទល្មើសដែលបានកើតឡើងរួមជាមួយព្យសនកម្មដែលបង្កអោយមានជាផលនៃបទល្មើសនោះ។ ភាពពិតប្រាកដនៃច្បាប់គឺជាទិដ្ឋភាពមួយដែលអាចបង្កាទប់ស្កាត់ និងដោះស្រាយបទល្មើសកុំឲ្យកើតមានឡើងដោយផ្អែកលើការដាក់ទោស និងការអនុវត្តទោស។ទន្ទឹមគ្នាផងដែរការដាក់ទោស វាជារឿងមួយដែលពិបាកចំពោះសង្គមដោយបានដាក់ទោសទៅលើប្រជាពលរដ្ឋខ្លួនដែលបានធ្វើខុសតែដើម្បីការពារនឹងធានានូវសណ្តាប់ធ្នាប់សង្គម ច្បាប់បានបញ្ញត្តិអំពីការដាក់ទោសនេះឡើងក្នុងគោលបំណងអប់រំ កែប្រែ ឲ្យចូលមករស់នៅក្នុងសង្គមសារជាថ្មី ឲ្យក្លាយទៅជាពលរដ្ឋល្អជាធនធានមួយសម្រាប់សង្គមជាតិទាំងមូលនាពេលអនាគត។

ការដាក់ទោស និងការអនុវត្តទោសវាជាគុមួយរួមផ្សំនៃការកកើតបទល្មើសផងដែរដោយសារនៅពេលដែលបុគ្គលនោះត្រូវបានអនុវត្តទោសរួចហើយតើជននោះអាចប្រព្រឹត្តបទល្មើសម្តងទៀតដែរ ឬទេ? ផ្អែកតាមការសិក្សាស្រាវជ្រាវលើប្រធានបទនេះ បទល្មើសកើនឡើង ឬថយចុះវាអាស្រ័យលើកត្តានៃការអនុវត្តជាក់ស្តែងប្រសិទ្ធិភាពនៃអ្នកអនុវត្តច្បាប់ និងស្ថានភាពរបស់បុគ្គលនោះផ្ទាល់ ។

**ការអនុវត្តជាក់ស្តែង** សំដៅទៅលើការដាក់ទោសត្រឹមត្រូវតាមច្បាប់ ព្យសនកម្មនៃបទល្មើសដែលបានកើតឡើងនោះបានបង្កគ្រោះថ្នាក់ដល់សង្គមខ្លាំងដែរ ឬទេ? ប្រសិនបើបទល្មើសមានលក្ខណៈមិនធ្ងន់ធ្ងររួមផ្សំជាមួយកាលៈទេសៈនៃបទល្មើសមិនបង្កជាផលនៃអំពើល្មើសខ្លាំងទៅតែបែរជាដាក់ទោសធ្ងន់ទៅវិញ។ នោះផលនៃ

ល្មើសដែលកើតឡើងពីការដាក់ទោសនឹងកើតមាននៅក្នុងសង្គមវិញជាក់ជាមិនខាន ដោយតាមរយៈការគុំកួននៃការដាក់ទោសស្ថានភាពផ្លូវចិត្ត។ល។ ដូចគ្នាផងដែរ បើបទល្មើសនោះមានលក្ខណៈធ្ងន់ធ្ងរខ្លាំងហើយការដាក់ទោសនោះបែរជាមានលក្ខណៈស្រាលវិញផលនៃបទល្មើសនោះ នឹងកើតមានជាបន្តបន្ទាប់ដោយសារតែជនល្មើសគិតថាការដាក់ទោសទាប ជនទាំងនោះមិនខ្លាចច្បាប់ជាដើមដែលគេហៅថា ផលនៃបទល្មើសដែលកើតមានឡើងតាមរយៈការដាក់ទោសដោយមិនមានភាពត្រឹមត្រូវ និងយុត្តិធម៌ស្របតាមស្ថានភាពសង្គម។

**ប្រសិទ្ធិភាពនៃអ្នកអនុវត្ត** ទោះបីជាមានច្បាប់ល្អប្រសើរយ៉ាងណាក៏ដោយប្រសិនបើអ្នកអនុវត្តនៅមានកម្រិតទាក់ទងទៅនឹងវិជ្ជាជីវៈរបស់ខ្លួនដោយមិនយកច្បាប់ទៅអនុវត្តទេ។ ប្រាកដណាស់បទល្មើសនឹងកើតមានឡើងដោយផ្អែកទៅតាមប្រសិទ្ធិភាពរបស់អ្នកអនុវត្តច្បាប់នោះ។ ការចូលរួមនៅក្នុងសង្គមដើម្បីបង្កាកុំអោយមានបទល្មើសកើតឡើង **គឺផ្អែកលើច្បាប់ជាស្នូល អ្នកអនុវត្តច្បាប់ជាគោល** និង**ការប្រតិបត្តិច្បាប់ជាដង្ហើម**នៃការទប់ស្កាត់បទល្មើសក៏ដូចជាការអភិវឌ្ឍន៍សង្គមអោយបានប្រសើរឡើង។ ប្រសិនបើមិនដូច្នេះទេបទល្មើសនឹងបន្តការកើតមានឡើង និងកើនឡើងជាក់ជាមិនខានផលនៃបទល្មើសដែលកើតឡើងចេញពីអ្នកអនុវត្តច្បាប់គឺធ្ងន់ធ្ងរដូចជា**ជម្ងឺមហារីករបស់សង្គម**អញ្ចឹង។

**ស្ថានភាពរបស់បុគ្គល** គឺជាអត្តចរិករបស់ជននោះដោយផ្អែកស្ថានភាព **មុនការអនុវត្តទោស** និង**ក្រោយការអនុវត្តទោស** សំដៅលើផលដែលកើតចេញពីការដាក់ទោស និងការអនុវត្តទោសតើបុគ្គលនោះទទួលបានអ្វីខ្លះ? មានដូចជាការទទួលបានការអប់រំ ការកែប្រែ ការរៀនសូត្រជំនាញផ្សេងៗដែលបុគ្គលកំពុងតែអនុវត្តទោស ហើយបុគ្គលនោះអាចយកជំនាញដែលខ្លួនបានរៀនសូត្រទាំងនោះមកប្រើប្រាស់បានទេ នៅពេលដែលខ្លួនវិលចូលក្នុងសង្គមវិញតាមរយៈការស្តារនីតិសម្បទានេះ។

ជាក់ស្តែងស្ថានភាពបុគ្គលជារឿងចាំបាច់បំផុតសម្រាប់វិធានការច្បាប់ អ្នកអនុវត្តច្បាប់ និងអង្គភាពដែលពាក់ព័ន្ធទាំងអស់ស្ថានភាពមួយផ្តោតលើការកែប្រែ លែងប្រព្រឹត្តបទល្មើស និងមួយទៀតការអប់រំនៅក្នុងពេលអនុវត្តទោស។ ចំពោះស្ថានភាពបុគ្គលមួយចំនួនគាត់មិនបានទទួលការអប់រំឬអ្វីផ្សេងនៅពេលដែលជនអនុវត្តទោសវាជាបញ្ហាមួយដែលត្រូវយកចិត្តទុកដាក់បំផុត នេះជាមូលហេតុនៃការមិនកែប្រែខ្លួនស្របតាមគោលគំនិតនៃច្បាប់នៅពេលដែលបុគ្គលនោះចេញមកវិញ។ ដោយសារកត្តាខ្លួនឯងមិនមានការងារធ្វើ កត្តាសង្គម មានការរើសអើង គួបផ្សំជាមួយនឹងជីវភាពរស់នៅប្រចាំថ្ងៃបុគ្គលនោះអាចនឹងប្រព្រឹត្តបទល្មើសនេះសារជាថ្មីជាក់ជាមិនខានប្រសិនបើជននោះមិនបានព្យាយាម កែខ្លួន និងមិនបានយកចិត្តទុកដាក់នៅពេលដែលជននោះអនុវត្តទោស។

ចំណុចសំខាន់ចំពោះស្ថានភាពរបស់បុគ្គលគឺនៅត្រង់ថា ជននោះមានគំនិតគុំកួន នឹងការដាក់ទោសនិងការអនុវត្តទោសទេ។ប្រសិនបើដូច្នេះផលនៃបទល្មើសនេះនឹងកើតមានឡើងបន្ទាប់ពីការអនុវត្តទោសបានបញ្ចប់ហើយបទល្មើសកើតឡើងតាមរយៈព្យសនកម្មនៃការដាក់ទោសដែលអាចនិយាយបានថា ការមិនរាងចាលនៃ

បទល្មើស ឬការប្រព្រឹត្តបទល្មើសតាមរូបភាពក្រោយការអនុវត្តទោសបានបញ្ចប់នេះជាបញ្ហាចំពោះសង្គមដោយត្រូវមានវិធានាការច្បាប់អប់រំកែប្រែមួយអោយល្អ ដោយស្របតាមច្បាប់ជាតិ និងកតិកាសញ្ញាអន្តរជាតិផងដែរ។

ចំពោះមូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គមកម្ពុជា វាឫសគល់នៃបទល្មើសដោយសារតែបទល្មើសបានកើតឡើងបានបង្កជាព្យសនកម្ម ដែលជាផលនៃបទល្មើសបានរំខានដល់ដំណើរការសង្គមដូចនេះការសិក្សាស្រាវជ្រាវប្រធានបទនេះគឺដើម្បីរកឲ្យឃើញថាតើបណ្តាលមកពីអ្វីខ្លះ? ដោយផ្អែកតាមការស្រាវជ្រាវមូលហេតុបានកើតឡើងតាមរយៈ**ការគ្រប់គ្រងប្រទេស** និងបណ្តាល**មកពីមជ្ឈដ្ឋាននៃការរស់នៅរបស់បុគ្គល**។

**ការគ្រប់គ្រងប្រទេស** វាជាផ្នែកមួយនៃមូលហេតុនៃការកកើតបទល្មើសដោយសារមានកត្តារួមផ្សំជាច្រើនដូចជាកត្តាសេដ្ឋកិច្ច នយោបាយ វប្បធម៌ ការអប់រំ ច្បាប់ និងការផ្សព្វផ្សាយនេះហើយដែលជាមូលលហេតុនៃការកកើតជាបទល្មើសនៅក្នុងសង្គមផ្អែកលើស្ថានភាពនៃការគ្រប់គ្រងប្រទេស។

**ចំណែកឯមជ្ឈដ្ឋាននៃការរស់នៅរបស់បុគ្គល** វិញគឺបានផ្សារភ្ជាប់ជាមួយបុគ្គលទាំងនោះដោយរួមមានស្ថានភាពភូមិសាស្ត្រនៃការរស់នៅមានដូចជា ការរស់នៅតំបន់អនាធិបតេយ្យ និងតំបន់ដាច់ស្រយាលជាដើមដែលជាហេតុបង្កលក្ខណៈងាយស្រួលដល់បទល្មើស ជាពិសេសជនល្មើសក្នុងការប្រព្រឹត្តបទល្មើសដូចជាទីកន្លែងការប្រើប្រាស់គ្រឿងញៀន ការជួញដូរពីព្រោះថាទីនោះមិនសូវមានសន្តិសុខសណ្តាប់ធ្នាប់ល្អដូចគ្នាផងចំពោះតំបន់ដាច់ស្រយាល គឺបង្កលក្ខណៈងាយស្រួលដល់ក្នុងការប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈ ជាដើម ។

**ការរីកចម្រើននៃបច្ចេកវិទ្យា** ជាកត្តាមួយដែលជាមូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គមមួយផ្អែកដោយផ្អែកតាមតាមវិទ្យាសាស្ត្រសម័យទំនើបដូចជា ទំនើបកម្មនៃសំភារៈនិយម សំដៅទៅលើសំភារៈដែលបង្កលក្ខណៈងាយស្រួលនៅក្នុងការប្រព្រឹត្តបទល្មើសដូចជាការប្រព្រឹត្តបទល្មើសតាមបែបប្រព័ន្ធឌីជីថលបច្ចេកវិទ្យា។

អាស្រ័យដូចបានសន្និដ្ឋានខាងលើ ផ្អែកលើមូលដ្ឋាននេះចំពោះការកកើតបទល្មើសនៅក្នុងសង្គមកម្ពុជាបណ្តាលមកពីកត្តាជាច្រើនដែលបានកើតមានឡើងនៅក្នុងសង្គមជាក់ស្តែងដែលតម្រូវឲ្យមានវិធានការបង្កា និងទប់ស្កាតដើម្បីកាត់បន្ថយបទល្មើសនៅក្នុងសង្គមដោយមានការចូលពីរួមពីគ្រប់ស្ថាប័ននានា ជាពិសេសគឺរាជរដ្ឋាភិបាលអន្តរាគមន៍ចំពោះមូលហេតុនេះ ជាការពិតណាស់សង្គមមួយអភិវឌ្ឍន៍ជឿនលឿនទៅមុខគឺអាស្រ័យលើការដឹកនាំបានល្អប្រសើរ ដោយមានឆន្ទៈជាតិនិយមពិតប្រាកដ ជាមួយនឹងការចូលរួមពីសំណាក់ប្រជាពលរដ្ឋទាំងអស់គ្នាក្នុងគោលបំណងអោយមានភាពរីកចម្រើនឡើងសម្រាប់កូនចៅជំនាន់ក្រោយ។

# អនុសាសន៍

# អនុសាសន៍

ឆ្លើយតបទៅនឹងការសិក្សាស្រាវជ្រាវប្រធានបទ **មូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គមកម្ពុជា** ក្នុងនាមខ្ញុំបាទជានិស្សិតម្នាក់ដែលបានឆ្លងកាត់ការសិក្សាស្រាវជ្រាវអំពីប្រធានបទមួយនេះទោះជាបីជាពេលនេះការសិក្សានេះមិនបានពេញលេញ និងគ្រប់ចំណុចក៏ដោយ។ ចំពោះការយល់ឃើញវាពិតជាមានភាពចាំបាច់បំផុតសម្រាប់ការគ្រប់គ្រងប្រទេសជាតិមួយប្រកបដោយសន្តិភាព មានសន្តិសុខ សណ្តាប់ធ្នាប់ល្អ និងមានភាពយុត្តិធម៌នៅក្នុងសង្គមដោយមិនមានភាពលំអៀងប្រកបដោយភាពត្រឹមត្រូវជាពិសេសដើម្បីទប់ស្កាត់ បង្កា កាត់បន្ថយនូវបទល្មើសកុំអោយកើតមានជាបន្តបន្ទាប់ទៀត។ ក្នុងនាមជាអ្នកដែលបានសិក្សាប្រធានបទនេះសូមជូនជាទស្សនៈដ៏ដូចជាដំណោះស្រាយដើម្បីអោយវិស័យព្រហ្មទណ្ឌមានភាពរីកចម្រើនខ្លាំង គួរគប្បីសិក្សាស្រាវជ្រាវអំពីមូលហេតុដែលជាហេតុនាំឲ្យបទល្មើសកើតឡើងថាតើបទល្មើសកើតឡើងដោយសារអ្វី? ក្នុងនាមយើងជាអ្នកជំនាញគប្បីត្រូវសិក្សាស្រាវជ្រាវអំពីប្រភពដែលជាមូលហេតុនេះដែរឬទេ? នេះជាសំណួរដែលក្នុងនាមយើងជាអ្នកបច្ចេកទេស អ្នកជំនាញ អ្នកថ្នាក់ដឹកនាំគួរតែសួរខ្លួនឯង។

ជាក់ស្តែងឆ្លើយតបទៅនឹងសំណួរដែលបានសួរការសិក្សាស្រាវជ្រាវ អំពីមូលហេតុនៃការកកើតបទល្មើសនេះគឺមានភាពចាំបាច់បំផុតក្នុងនាមជាអ្នកស្រាវជ្រាវ អ្នកបច្ចេកទេស អ្នកជំនាញ។ ព្រោះថាបើសិនជាយើងចង់ព្យាបាលជម្ងឺអ្វីមួយយើងត្រូវដឹងអំពីប្រភពនៃជម្ងឺនោះ ក៏ដូចជាមូលហេតុដែលជម្ងឺនោះកើតឡើងទើបយើងអាចព្យាបាលវាជាដូចគ្នាផងដែរចំពោះការកកើតនៃបទល្មើស ឬការកើនឡើងនៃបទល្មើសមួយចំនួនយើងត្រូវដឹងអំពីមូលហេតុនៃការកើតនេះទើបយើងអាចមានវិធានការ និងដំណោះស្រាយបានល្អប្រសើរជៀសវាងការអនុវត្តមិនបានល្អនិងមិនចំគោលដៅដែលចង់បាន។

តាមរយៈការសង្កេតនៅក្នុងប្រទេសកម្ពុជារបស់យើងសព្វថ្ងៃគឺមានភាពខ្វះខាត នូវអ្នកជំនាញចំពោះវិស័យព្រហ្មទណ្ឌចំពោះការស៊ើបអង្កេតដែលពាក់ព័ន្ធបទល្មើសពិសេសៗមួយចំនួន ការលើកឡើងនេះមិនមែនមានន័យថាយើងមិនមានទេតែមានតិចតួច។ ជាពិសេសគឺសម្ភារៈនៅក្នុងការសិក្សាស្រាវជ្រាវអំពីបទល្មើសសំភារៈសិក្សាស្រាវជ្រាវមន្ទីរពិសោធន៍ដែលទាក់ទងការវិនិច្ឆ័យលើបទល្មើស ឬជាការសិក្សាដើម្បីរៀនសូត្រគឺមានភាពខ្វះខាតបំផុតដូចជាការសិក្សាទៅ មុខវិជ្ជាឧក្រិដ្ឋវិទ្យា ឧក្រិដ្ឋនិច្ឆ័យជាដើមគឺអ្នកសិក្សាបានតែដឹងទ្រឹស្តីមួយចំនួន។ ចំណែកឯការអនុវត្តសឹងតែមិនមានផងព្រោះថា នៅតាមបណ្តាលកន្លែងបណ្តុះបណ្តាលដូចជាសាលារៀនមួយចំនួនមានតែមុខវិជ្ជាបង្រៀនចំពោះសំភារៈមិនទាន់មាន បើសិនជាចង់ធ្វើការពិសោធន៍អ្វីមួយត្រូវទៅសូមកន្លែងណាមួយដូចជាមន្ទីពេទ្យ កន្លែងពិសោធន៍ផ្សេងទៀតវាមានភាពលំបាកណាស់ពេលខ្លះមិនបានផង។

ជាទស្សនៈនៅក្នុងការអភិវឌ្ឍន៍វិស័យទាំងនេះរួមជាមួយការបង្កា ទប់ស្កាត់ និងកាត់បន្ថយនូវបទល្មើសនៅក្នុងសង្គមយើងគួរមានវិធានការមួយចំនួនដូចខាងក្រោម៖

- **យុទ្ធសាស្ត្រដោះស្រាយចំពោះការកកើតបទល្មើស**
  - ➢ បង្កើនការសិក្សាស្រាវជ្រាវអំពីមូលហេតុនៃការកកើតបទល្មើសនៅក្នុងសង្គម
  - ➢ ការបង្កើតស្ថាប័នជំនាញ ឯកទេសបច្ចេកទេសវិស័យព្រហ្មទណ្ឌទូទាំងប្រទេស
  - ➢ ការបង្កើនកិច្ចសហប្រតិបត្តិការណ៍ជាតិ និងអន្តរជាតិ ពាក់ព័ន្ធវិស័យព្រហ្មទណ្ឌ
  - ➢ បង្កើនសំភារៈនៅក្នុងមន្ទីរពិសោធន៍ ឫកន្លែងសិក្សាស្រាវជ្រាវឲ្យបានគ្រប់គ្រាន់
  - ➢ លើកទឹកចិត្តដល់អ្នកសិក្សាស្រាវជ្រាវអោយមានភាពត្រឹមត្រូវ ឯករាជ្យ មានក្រមសីលធម៌ វិជ្ជាជីវៈ និងទទួលខុសត្រូវចំពោះការធ្វើខុសចំពោះមុខច្បាប់
  - ➢ បង្កើតច្បាប់ ឫបទដ្ឋាន ដែលពាក់ព័ន្ធបទល្មើសដែលកើតមានថ្មីៗនៅក្នុងសង្គម
- **ដំណោះស្រាយកុំអោយមានការសិក្សានូវមានកម្រិត**
  - ➢ ការសិក្សាស្រាវជ្រាវត្រូវមានការរួមពីថ្នាក់ជាតិ ក្រោមជាតិ ទូទាំងប្រទេសចូលរួមសហការគ្នា
  - ➢ មានកិច្ចសហប្រតិបត្តិការណ៍ ការផ្លាស់ប្តូរការសិក្សាស្វែងយល់ពីការកកើតបទល្មើសថ្មីៗ ជាមួយអន្តរជាតិ ដូចជា ប្រទេសក្នុងតំបន់ និងកំរិតអន្តរជាតិដទៃ ដើម្បីអភិវឌ្ឍន៍វិស័យព្រហ្មទណ្ឌ
  - ➢ ជម្រុញឲ្យមានកិច្ចសហប្រតិបត្តិការណ៍ រវាងស្ថាប័ននៅក្នុងស្រុកទាំងអស់ដែលទាក់ទងគ្នា
  - ➢ ជម្រុញការអនុវត្តលើវិស័យយុត្តិធម៌ ដូចជា ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ស្ថាប័នតុលារ និងស្ថាប័នជំនាញផ្សេងៗ ដែលកំពុងតែធ្វើកិច្ចការពាក់ព័ន្ធបទល្មើស។

សម្រាប់ការសិក្សាសារណាលើប្រធានបទមួយនេះនៅមានភាពខ្វះខាត និងមិនទាន់គ្រប់ជ្រុងជ្រោយឡើយដោយនៅមានចំណុចដែលត្រូវសិក្សាស្រាវជ្រាវបន្តជាច្រើនទៀត។ និងសម្រាប់អ្នកសិក្សាស្រាវជ្រាវក្រោយៗដែលមានបំណងចង់អភិវឌ្ឍន៍លើវិស័យព្រហ្មទណ្ឌត្រង់ចំណុចណាមួយដើម្បីរួមគ្នាក្នុងការកសាងប្រទេសជាតិមួយ ដែលមានវិស័យព្រហ្មទណ្ឌ ជួយសម្រួលវិស័យយុត្តិធម៌ ស្ថាប័នតុលាការមួយដែលមានលក្ខណៈបែបវិទ្យាសាស្ត្រ។

# ឯកសារយោង

# ឯកសារយោង

## ១. បទដ្ឋានគតិយុត្តិអន្តរជាតិ

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦
- អនុសញ្ញាស្តីពីការប្រឆាំងអំពើទារុណកម្ម និងអំពើប្រទណ្ឌកម្មផ្សេងៗដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤

## ២. សៀវភៅ និងឯកសារផ្សេងៗ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣ ដល់ បច្ចុប្បន្ន)
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីអំពីពន្ធនាគារ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១
- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥
- ច្បាប់ស្តីពីការអប់រំ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៩
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២
- ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០
- ច្បាប់ស្តីអំពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ចុះថ្ងៃទី១៦ ខែមិថុនាឆ្នាំ២០២០
- ច្បាប់ស្តីពីការស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០០៥
- សៀវភៅឧក្រិដ្ឋវិទ្យា ( លោកបណ្ឌិត ស៊ិន រិទ្ធ)
- សៀវភៅ ឧក្រិដ្ឋនិច្ច័យ (លោកបណ្ឌិត ឯក ឆេង ហួត)
- សៀវភៅ កោសល្យវិច្ច័យតាមនីតិវិធីវេជ្ជសាស្ត្រកម្ពុជា (លោកបណ្ឌិត ហ៊ង ឡៃប៉ាប៉ូ)

## ៣. វចនានុក្រម

- វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត
- សទ្ទានុក្រមពាក្យច្បាប់ ព្រហ្មទណ្ឌ